# ជីវវិទ្យាសត្វព្រៃ

# Wildlife Biology



## សញ្ញាណគ្រឹះនៃទស្សនៈទានអំពីវិទ្យាសាស្ត្រសត្វព្រៃ

## Primary Concepts of Wildlife Science

លិ វុឌ្ឍី (LIC Vuthy)



# ជីវវិទ្យាសត្វព្រៃ

# Wildlife Biology

## សញ្ញាណគ្រឹះនៃទស្សនៈទានអំពីវិទ្យាសាស្ត្រសត្វព្រៃ

## Primary Concepts of Wildlife Science


ម.ព.ឯ.ក A!DOC

Code: 172-005

Date:

Donated by:



លិ វុឌ្ឍី (LIC Vuthy)






ភ្នំពេញ ២០០៩

រូបភាពលើក្របសៀវភៅថតដោយ : លោក លិ វុឌ្ឍី

សំរាប់ជាឯកសារយោង : លិ វុឌ្ឍី ឆ្នាំ ២០០៩ ។ ជីវវិទ្យាសត្វព្រៃ ។ ភ្នំពេញ ប្រទេសកម្ពុជា

៨.១ កំណើនប៉ូប៉ុឡាស្យុង ............................................................ ១៤៥
៨.១.១ អត្រាសក្ដានុពលជីវៈនៃកំណើនមិនស្ថិតក្នុងលក្ខខ័ណ្ឌ
មរណៈភាពដង់ស៊ីតេអាស្រ័យ ............................................ ១៤៩
៨.១.២ កំណើនប៉ូប៉ុឡាស្យុងមិនស្របតាមអត្រាសក្ដានុពលជីវៈ
នៃកំណើន ............................................................ ១៤៩
៨.១.៣ ការខកខានមិនបានរក្សាលំនឹងនៅចំណុចសមត្ថភាពទ្រទ្រង់ ...... ១៥១
៨.២ ខួបប្រចាំឆ្នាំ ............................................................ ១៥២
៨.២.១ បរិមាណលើស ............................................................ ១៥២
៨.៣ ស្ថេរភាពនៃប៉ូប៉ុឡាស្យុង ............................................................ ១៥៣
៨.៣ .ក ប៉ូប៉ុឡាស្យុងស្ថេរភាពប្រៀបធៀប ............................................ ១៥៤
៨.៣ .ខ ប៉ូប៉ុឡាស្យុងខួប ............................................................ ១៥៤
៨.៣ .គ ប៉ូប៉ុឡាស្យុងភ្លាត់ ............................................................ ១៥៤
**ជំពូក ៩ របៀបចំប៉ូប៉ុឡាស្យុងសត្វព្រៃ** ............................................ ១៥៦
៩.១ សក្ដានុពលសមត្ថភាពទ្រទ្រង់ ............................................................ ១៥៦
៩.២ ភាពផ្សេងៗគ្នានៃដង់ស៊ីតេសត្វព្រៃ ............................................ ១៥៨
៩.៣ ការគ្រប់គ្រងសត្វព្រៃដោយការបរបាញ់ ............................................ ១៥៩
៩.៣.១ ការបរបាញ់ជាអាហារគ្រួសារ ............................................ ១៥៩
៩.៣.២ ការបរបាញ់ជាលក្ខណៈពាណិជ្ជកម្ម ( សំរាប់ទីផ្សារ) ................ ១៦០
៩.៣.៣ ការបរបាញ់ជាលក្ខណៈកីឡា ............................................ ១៦១
៩.៣.៤ ប្រភេទកំពុងរងគ្រោះថ្នាក់ ............................................ ១៦២
៩.៣.៥ ប្រភេទងាយរងគ្រោះ ............................................................ ១៦៣
៩.៤ ការត្រួតពិនិត្យនានាភាពនៃសត្វព្រៃ ............................................ ១៦៣
៩.៤.១ ការបង្កើនចំនួនសត្វព្រៃសំរាប់កីឡាប្រមាញ់ ................................ ១៦៣
៩.៤.២ ការបង្កើនសត្វព្រៃសំរាប់ពាណិជ្ជកម្ម ............................................ ១៦៣
៩.៤.៣ ប្រភេទសត្វរាតត្បាតប្រមាញ់ ............................................ ១៦៤
**ជំពូក ១០ ធនធានសត្វព្រៃ និងការប្រើប្រាស់ដីធ្លី** ............................................ ១៦៥
១០.១ ភាពមាំទាំនៃតំបន់អភិរក្ស ( តំបន់ការពារ និងតំបន់ព្រៃការពារ) ....... ១៦៥
១០.២ កំណើនមនុស្ស ............................................................ ១៦៧

# Executive Summary

**The 'Wildlife Biology' book is providing about:**

- Cambodia wildlife richness and historical anecdote of wildlife presence throughout Cambodia,
- Wildlife management and preliminary survey methods,
- Concept of protected areas establishment and design for wildlife management and conservation. Factors affecting on population growth, habitat, and land use options is being discussed.
- Wildlife population growth theory and examples.

This is the first ever book in Khmer language discussing on wildlife ecological concept and management. The book is attempted to help students, rangers, and people who would like to be a better wildlife manager. Having read this book students, rangers, and wildlife managers will improve their wildlife and forest sustainable management knowledge. The book will help Cambodians, who usually lack of book to read, to speed up their own stands in this field that is needed among conservation and sustainable development agencies.

**LIC Vuthy**

Wildlife and Environment Management Research Specialist

# ពាក្យបំព្រួញ

| | |
|---|---|
| **CI** | **Conservation International** |
| **FAO** | **Food and Agriculture Organization of the United Nations** |
| **IUCN** | **International Union for Conservation of Nature** |
| **FFI** | **Fauna and Flora International** |
| **ONF** | **Office National des Forêts** |
| **WCS** | **Wildlife Conservation Society** |
| **WWF** | **World Wildlife Funds** |

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម ទី សុគន្ធ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ ដែលបានផ្តល់នូវការណែនាំ និងតំរង់ទិសក្នុងសំណេរនេះ ។ អំណរគុណយ៉ាងស្មោះជូនចំពោះ លោក ឆេង គឹមស៊ុន អនុប្រធានរដ្ឋបាលព្រៃឈើ និងព្រឹទ្ធបុរស វន មុនិន្ទ នៃមហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដែលបានពិនិត្យខ្លឹមសារ និងកែលំអគំនិតមួយចំនួនក្នុងស្នាដៃនេះ ។

អំណរគុណដ៏សំបើមជូនចំពោះ លោក ម៉េង មុនីរក្ស លោក ជា ណារ៉េត លោក គ្រី ម៉ះផល លោក វ័ត្ត ប៊ុនធឿន លោក ប៉ុល ចាន់ថា លោក អ៊ូ រតនៈ លោក ហុង ចំណាន លោក តាន់ សេដ្ឋា ដែលបានជួយអាន និងផ្តល់មតិស្ថាបនាជាច្រើនដល់ស្នាដៃនេះ ។

សូមឧទ្ទិសស្នាដៃនេះជូន លោកឪពុក អ្នកម្តាយ ភរិយា និងកូនរបស់ខ្ញុំបាទ ។

# អារម្ភកថា

នៅចុងទសវត្សឆ្នាំ ១៩៩០ និងអំឡុងទសវត្សឆ្នាំ ២០០០ នេះ យើងឃើញមានការយកចិត្តទុកដាក់កាន់តែច្រើនឡើងអំពីការគ្រប់គ្រងធនធានធម្មជាតិឱ្យប្រកបដោយនិរន្តរភាព និងការអភិរក្សធនធានធម្មជាតិ ។ ប៉ុន្តែ យើងនៅខ្វះឯកសារជាច្រើនដែលជាបទពិសោធន៍ ឬជាការតំរង់ទិសសំរាប់ការគ្រប់គ្រងធនធានធម្មជាតិ ។ ជាញឹកញយ ពីជំនាន់មួយទៅជំនាន់មួយទៀត កំហុសជាច្រើនត្រូវបានគេជួបប្រទះសារឡើងវិញដដែលជាដដែល ។ ហេតុនេះ ការចៀសវាងនូវអ្វីដែលខុសជាការងារចាំបាច់ ។ ដើម្បីជាវិភាគទានដល់ ការចូលរួមធ្វើឱ្យសំរេចគោលបំណងគ្រប់គ្រងធនធានធម្មជាតិឱ្យបានកាន់តែប្រសើរឡើង សៀវភៅ "**ជីវវិទ្យាសត្វព្រៃ**" នេះនឹងផ្តល់ដល់អ្នកអានសិស្ស និស្សិតនូវទស្សនៈបឋម១អំពីអេកូឡូស៊ីសត្វព្រៃ និងចំណេះទាក់ទងជាប្រព័ន្ធរបស់វា ។ សៀវភៅនេះនឹងផ្តល់សញ្ញាណអេកូឡូស៊ី ការវិវត្តន៍ និងប្រវត្តិរបស់សត្វព្រៃ ពិសេសនៅកម្ពុជាដែលអ្នកអាន ពិសេសសិស្ស និស្សិត ឬអ្នកជំនាញសត្វព្រៃ-ព្រៃឈើគួរយល់ដឹង ។ សៀវភៅនេះនឹងផ្តល់ជូនលោកអ្នកនូវចំណេះដឹងដ៏សំខាន់អំពីបរិបទផលប្រយោជន៍សត្វព្រៃ និងវិភាគទានរបស់វាចំពោះជីវភាពមនុស្សជាតិ ។

ប្រវត្តិព្រឹត្តិការណ៍សំខាន់ៗនៃការគ្រប់គ្រងធនធានធម្មជាតិដូចជាដំណើរការបង្កើតតំបន់ការពារ ច្បាប់ ឬលិខិតបទដ្ឋានផ្សេងៗទៀត ក៏មានអធិប្បាយនៅក្នុងស្នាដៃនេះដែរ ។ ការផ្តួចផ្តើមគំនិត ការបន្តការគ្រប់គ្រង និងការចាត់ថ្នាក់តំបន់ការពារទាំង ២៣កន្លែង (៣.៣លានហិត) ឬព្រៃការពារទាំង ៦កន្លែង (១.៣៥លានហិត) ក៏បានលើកមកបរិយាយនៅក្នុងពេលនេះដែរ ។

យើងខ្ញុំសង្ឃឹមថាស្នាដៃនេះនឹងជួយស្មារតីយល់ដឹងអំពីអេកូឡូស៊ីសត្វព្រៃ និងតម្រូវការនានារបស់សត្វព្រៃ ដើម្បីវាមានអត្ថិភាពជាបន្តទៀត នៅលើផែនដីនេះ ដល់លោកអ្នកបានជាដើមទុនក្នុងការបន្តអាជីពអ្នកគ្រប់គ្រងធនធានធម្មជាតិ ទាំងនៅកម្ពុជា ទាំងនៅលើសកលលោកជាពុំខាន ។ ស្នាដៃនេះមានគោលបំណងយ៉ាងសំខាន់ជាជំនួយស្មារតីដល់សាស្ត្រាចារ្យបង្រៀនមុខ

# មាតិកា


សេចក្តីថ្លែងអំណរគុណ ............ i
អារម្ភកថា ............ ii
សេចក្តីផ្តើម ............ iv
ជំពូក ១ សត្វព្រៃ និងមនុស្ស ............ ១
១.១ ការប្រមើលមើលអំពីមនុស្សបឋម ............ ២
១.២ ប្រវត្តិ ............ ៥
១.២.ក ទំនើបកម្មកសិកម្ម ............ ៥
១.២.ខ ទំនើបកម្មសង្គម ............ ៦
១.៣ តម្លៃសត្វព្រៃ ............ ៦
១.៣.១ តម្លៃផ្ទាល់ ( តម្លៃពាណិជ្ជកម្ម ឬទំនិញ) ............ ៧
១.៣.២ តម្លៃប្រយោល ............ ៩
១.៣.៣ តម្លៃសោភ័ណ្ឌ និងប្រពៃណីជនជាតិដើមភាគតិច ............ ១៣
១.៣.៤ តម្លៃវិទ្យាសាស្ត្រ ............ ១៥
១.៤ ធនធានធម្មជាតិសត្វព្រៃ ............ ១៧
ជំពូក ២ សត្វព្រៃនៅកម្ពុជា ............ ២០
២.១ ប្រវត្តិនៃការគ្រប់គ្រងព្រៃឈើ-សត្វព្រៃ ............ ២១
២.១.១ សម័យអាណាព្យាបាលបារាំង ............ ២៤
២.១.២ ឆ្នាំ ១៩៥០ ដល់ ១៩៧០ : ការដាក់តាំងតំបន់បំរុងសត្វព្រៃ ............ ២៩
២.១.៣ ពីសម័យ ១៩៧០ ដល់ បច្ចុប្បន្ន ............ ២៩
២.២ បញ្ហាប្រឈមចំពោះសត្វព្រៃ ............ ៣០
២.២.១ បញ្ហាក្នុងតំបន់ ............ ៣១
២.២.២ បញ្ហានៅកម្ពុជា ............ ៣៣
ក. តម្រូវការដីកសិកម្ម ............ ៣៣
ខ. ឈ្មោះភូមិសាស្ត្រនានា និងអតីតវត្តមានព្រៃឈើ ............ ៣៦
គ. ឈ្មោះភូមិសាស្ត្រនានា និងអតីតវត្តមានសត្វព្រៃ ............ ៤០
ឃ. សករាជព្រៃឈើសំខាន់ៗ ............ ៤១
២.៣ ការអនុវត្តន៍ច្បាប់គ្រប់គ្រងសត្វព្រៃ ............ ៤៦

# មាតិកា


**សេចក្តីថ្លែងអំណរគុណ** ............................................ i

**អារម្ភកថា** ............................................ ii

**សេចក្តីផ្តើម** ............................................ iv

**ជំពូក ១ សត្វព្រៃ និងមនុស្ស** ............................................ ១

១.១ ការប្រមើលមើលអំពីមនុស្សបឋម ............................................ ២

១.២ ប្រវត្តិ ............................................ ៥

១.២.ក ទំនើបកម្មកសិកម្ម ............................................ ៥

១.២.ខ ទំនើបកម្មសង្គម ............................................ ៦

១.៣ តម្លៃសត្វព្រៃ ............................................ ៦

១.៣.១ តម្លៃផ្ទាល់ ( តម្លៃពាណិជ្ជកម្ម ឬទំនិញ) ............................................ ៧

១.៣.២ តម្លៃប្រយោល ............................................ ៩

១.៣.៣ តម្លៃសោភ័ណ្ឌ និងប្រពៃណីជនជាតិដើមភាគតិច ............................................ ១៣

១.៣.៤ តម្លៃវិទ្យាសាស្ត្រ ............................................ ១៥

១.៤ ធនធានធម្មជាតិសត្វព្រៃ ............................................ ១៧

**ជំពូក ២ សត្វព្រៃនៅកម្ពុជា** ............................................ ២០

២.១ ប្រវត្តិនៃការគ្រប់គ្រងព្រៃឈើ-សត្វព្រៃ ............................................ ២១

២.១.១ សម័យអាណាព្យាបាលបារាំង ............................................ ២៤

២.១.២ ឆ្នាំ ១៩៥០ ដល់ ១៩៧០ : ការដាក់តាំងតំបន់បំរុងសត្វព្រៃ ............................................ ២៩

២.១.៣ ពីសម័យ ១៩៧០ ដល់ បច្ចុប្បន្ន ............................................ ២៩

២.២ បញ្ហាប្រឈមចំពោះសត្វព្រៃ ............................................ ៣០

២.២.១ បញ្ហាក្នុងតំបន់ ............................................ ៣១

២.២.២ បញ្ហានៅកម្ពុជា ............................................ ៣៣

ក. តម្រូវការដីកសិកម្ម ............................................ ៣៣

ខ. ឈ្មោះភូមិសាស្ត្រនានា និងអតីតវត្តមានព្រៃឈើ ............................................ ៣៦

គ. ឈ្មោះភូមិសាស្ត្រនានា និងអតីតវត្តមានសត្វព្រៃ ............................................ ៤០

ឃ. សករាជព្រៃឈើសំខាន់ៗ ............................................ ៤១

២.៣ ការអនុវត្តន៍ច្បាប់គ្រប់គ្រងសត្វព្រៃ ............................................ ៤៦

# សេចក្តីផ្តើម

ក្នុងរយៈពេលនៃចុងសតវត្សទី ២០ និងដើមសតវត្សទី ២១ យើងឃើញមានការកើនឡើងជាលំដាប់នៃការនិយមគយគន់ ទស្សនា និងការចិញ្ចឹមសត្វព្រៃ ដើម្បីជាការលំហែ ឬដំណើរកំសាន្ត ។ ដោយឃើញទំនោរបែបនេះ និងដើម្បីបង្កើនការបំរើវិស័យនេះឱ្យសមស្របតាមតម្រូវការ យើងឃើញមានការកើនឡើងនៃចំនួនសួនសត្វ និងស្តង់ដានៃការគ្រប់គ្រងសត្វព្រៃ ។ ការគ្រប់គ្រងសួនសត្វមានគោលបំណងបំរើវិស័យទេសចរណ៍ផង ការអប់រំផង និងការអភិរក្សផង ។ រហូតមកដល់ពេលនេះ នៅកម្ពុជាយើងឃើញមានសួនសត្វ ចំនួន ៤កន្លែង ក្នុងនោះមួយកន្លែងចាត់ចែងដោយរដ្ឋ (រដ្ឋបាលព្រៃឈើ/ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ) ហើយចំនួន ៣កន្លែងទៀតចាត់ចែងដោយក្រុមហ៊ុន (ឬឯកជន) ។ រីឯការគ្រប់គ្រងសត្វព្រៃដែលហៅថា "អភិរក្សក្នុងតំបន់" គឺចាត់ចែងដោយស្ថាប័នរដ្ឋាភិបាល (រដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន)។ ជាការពិត ការចាត់ចែងគ្រប់គ្រងសត្វព្រៃ (អភិរក្សក្នុងតំបន់) ក៏មានការចូលរួមពីបណ្តាមូលនិធិ ឬបណ្តាអង្គការមិនមែនរដ្ឋាភិបាល (Non-Governmental Organization) ផងដែរ ។

អ្នកទីក្រុងភាគច្រើនដែលធុញថប់នឹងភាពមមាញឹកនៃទីក្រុងនាំឱ្យគេចេញក្រៅក្រុងដើម្បីទស្សនាសួនសត្វ ឬឧទ្យានជាតិ ។ ចំពោះអ្នកខ្លះដែលអាចមានពេលច្រើន ពួកគេចំណាយពេល ២-៣ថ្ងៃសំរាប់ដំណើរកំសាន្តសត្វព្រៃ ចំពោះអ្នកខ្លះទៀត (ដែលមានចំនួនលើសលប់) ទស្សនាសត្វព្រៃក្រៅក្រុងរយៈពេលមួយថ្ងៃដោយវិលត្រឡប់មកលំនៅដ្ឋានរបស់គេវិញនៅពេលល្ងាច ។ មនុស្សមួយចំនួនទៀត បើទោះជាពួកគេទៅទស្សនាសត្វព្រៃនៅសួនសត្វ ឬឧទ្យានហើយក៏ដោយក៏គេនៅតែបន្ថែមការចិញ្ចឹមសត្វព្រៃ (ពិសេសសត្វស្លាប) នៅតាមគេហដ្ឋានរបស់ខ្លួនដែរ ។ ប៉ុន្តែដោយសារការចិញ្ចឹមសត្វព្រៃ ពិសេសប្រភេទសត្វមានដោយកម្រនៅតាមគេហដ្ឋាន ត្រូវបានច្បាប់ហាមឃាត់ នោះចំនួននៃការចិញ្ចឹមនោះបានថយចុះវិញ ។ ហេតុនេះនៅកម្ពុជា ក៏ដូចនៅបណ្តាប្រទេសដទៃច្រើនទៀតដែរ ឱកាសដែលល្អជាងគេ គឺការទស្សនាសត្វព្រៃតាមតំបន់ឧទ្យាន ឬតំបន់អភិរក្សនានា ។

វិជ្ជាការគ្រប់គ្រងសត្វព្រៃ និស្សិតនៃមុខវិជ្ជានេះ និងមុខវិជ្ជាបរិស្ថាន-អេកូឡូស៊ីព្រៃឈើ-សត្វព្រៃ ជាពិសេសមន្ត្រី និងបុគ្គលិកដែលបំរើការងារក្នុងវិស័យគ្រប់គ្រងធនធានធម្មជាតិ ។ សូមឱ្យការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាពសណ្ឋិតនៅនឹងបុគ្គលគ្រប់រូប គ្រប់ស្រទាប់វណ្ណៈ ដើម្បីឱ្យប្រព័ន្ធអេកូឡូស៊ី-បរិស្ថាននៅបន្តផ្តល់អត្ថិភាពដល់ប្រភេទសត្វនានា រួមទាំងមនុស្សផងឱ្យរស់រានមានជីវិតនៅលើផែនដីនេះជាមួយគ្នា តរៀងទៅ ។

លិ វុឌ្ឍី

អ្នកជំនាញស្រាវជ្រាវ និងការគ្រប់គ្រងធនធានធម្មជាតិ-បរិស្ថាន

៥.៣ លក្ខណៈសមមូលនៃប៉ូប៉ុឡាស្យុង ........ ១២១
៥.៣.១ ស្តុង ........ ១២២
៥.៣.២ ផលិតផល ........ ១២២

ជំពូក ៦ ដែនជីសត្វព្រៃ និងចលនារបស់វា ........ ១២៤
៦.១ ចលនាខាងក្នុង ........ ១២៥
៦.១.១ អន្តោប្រវេសន្ត ........ ១២៥
៦.១.២ ដែនរស់នៅ ........ ១២៧
៦.២ ចលនាខាងក្រៅ ........ ១២៨
៦.៣ ទំហំក្រុម និងទីកន្លែង ........ ១២៩
៦.៣.១ ដែនដី ........ ១៣០
៦.៤ សក្តានុពលភាពនៃការតាំងទីថ្មី១ និងចលនា ........ ១៣១
៦.៥ ច្រករបៀង ........ ១៣២

ជំពូក ៧ វិធីសាស្ត្រសិក្សាសត្វព្រៃ ........ ១៣៣
៧.១ សំភារៈមូលដ្ឋាន ........ ១៣៤
៧.១.១ សៀវភៅកត់ត្រា ........ ១៣៤
៧.១.២ ផែនទីអង្កេត ........ ១៣៥
៧.១.៣ នាមវល្លី ( គាក់សូណូមី) ........ ១៣៥
៧.១.៤ លក្ខណៈស្តាទីស្ទីក (statistical consideration) ........ ១៣៦
៧.២ ការរាប់ប៉ូប៉ុឡាស្យុង ........ ១៣៧
៧.២.១ ការរាប់សត្វព្រៃដោយតំបន់គំរូ ........ ១៣៨
៧.២.២ ដាន និងស្លាកស្នាម ........ ១៣៨
៧.២ អត្រា និងសន្ទស្សន៍ ........ ១៤០
៧.៣ ចលនា ........ ១៤១
៧.៤ លក្ខណៈវិនិច្ឆ័យភេទ និងអាយុ ........ ១៤២
៧.៥ ការបន្តពូជ និងកំណើត ........ ១៤៣
៧.៦ មរណៈភាព ........ ១៤៣
៧.៧ អាកប្បកិរិយាស្វែងរកអាហារ ........ ១៤៤

ជំពូក ៨ ឌីណាមិកប៉ូប៉ុឡាស្យុងសត្វព្រៃ ........ ១៤៥

៤.១.៤ អន្តរភាពនៃអាហារ គំរប និងទឹក ..................................................... ៨៥
៤.១.៥. កត្តាកំណត់ ..................................................................................... ៨៦
៤.២ តំណភាពជីវៈ និងសត្វព្រៃ ............................................................................ ៨៧
៤.២.១ អ៊ីដ្រូសេរេ និងវារីសត្វ ......................................................................... ៨៨
៤.២.២ តំណភាពវាលស្មៅ ព្រៃឈើ និងភាពសំបូរបែបសត្វតិណាសី.........៩៣
ក. គ្គីម៉ាក្ស និងស្ថេរភាព..................................................................... ៩៧
ខ. ចំណាត់ថ្នាក់តំណភាពនៃសត្វព្រៃ ....................................................៩៨
៤.២.៤ ប្រភេទសត្វព្រៃគ្លីម៉ាក្ស ឬប្រភេទសត្វស្មសាន្ត.........................................៩៨
៤.២.៥ ប្រភេទសត្វព្រៃពាក់កណ្តាលតំណភាព ...............................................៩៩
៤.២.៦ ប្រភេទសត្វព្រៃក្នុងតំណភាព ........................................................១០០
**ជំពូក ៥ លក្ខណៈប៉ូប៉ុឡាស្យុង**.............................................................................. ១០១
៥.១ ដង់ស៊ីតេ និងជីវម៉ាស.......................................................................... ១០១
៥.២ រចនាសម្ព័ន្ធប៉ូប៉ុឡាស្យុង................................................................................១០៥
៥.២.ក កំណើត...........................................................................................១០៨
ក ១. ទំហំសំណុំកូន...................................................................................១០៩
ក ២. ចំនួនសំណុំកូន ( កំណើត) ក្នុង ១ឆ្នាំៗ.................................................. ១១០
ក ៣. អប្បរមា និងអតិបរមានៃអាយុកាលរបស់មេ .......................................១១១
ក ៤. អត្រាភេទ និងអាកប្បកិរិយាកាលញី-ឈ្មោល .......................................១១១
ក ៥. ដង់ស៊ីតេ និងការបន្តពូជនៃប៉ូប៉ុឡាស្យុង..................................................១១២
ក ៦. កំណើតអតិបរមា...................................................................................១១២
៥.២.ខ មរណៈភាព.......................................................................................១១៣
ខ.១ រំពាសី.................................................................................................១១៣
ខ.២ ជម្ងឺ និងប៉ារ៉ាស៊ីត............................................................................... ១១៥
ខ.៣ អាកាសធាតុ.........................................................................................១១៦
ខ.៤ ទុរ្ភិក្ស ( ភាពខ្វះអាហារ) ..................................................................... ១១៦
ខ.៥ ភាពស្ងួត................................................................................................១១៧
ខ.៦ ប្រមាញ់ ............................................................................................. ១១៨
ខ.៧ ឥទ្ធិពលដទៃទៀតលើមរណៈភាព.......................................................... ១១៨

ដើម្បីឱ្យនៅតែមានសត្វព្រៃសំរាប់ការទស្សនា ការប្រើប្រាស់ និងការអភិវឌ្ឍន៍ បុគ្គលរាល់រូប ពិសេសអ្នកដែលចូលចិត្តសត្វព្រៃ គួរមានសញ្ញាណអំពីជីវសាស្ត្រសត្វព្រៃ ទំនាក់ទំនងរវាងសត្វព្រៃនិងមនុស្ស ហើយនិងកត្តានានាដែលនាំឱ្យចំនួនសត្វព្រៃអាចរក្សាបានស្ថេរភាពរបស់វានៅលើភពផែនដីនេះ ។

# ជំពូក ១ សត្វព្រៃ និងមនុស្ស

នៅពេលនេះគេអាចចែកមនុស្សជាពីរក្រុមគឺ ក្រុមមនុស្សដែលរស់នៅបានដោយមិនចាំបាច់ សត្វព្រៃ និងមនុស្សដែលអាចរស់នៅបានដោយចាំបាច់ត្រូវមានសត្វព្រៃ។ មនុស្សក្រុមទីពីរអាចរស់រានមានជីវិតបានលុះត្រាតែមានសត្វព្រៃ ។ ក្រុមមនុស្សដែលចាត់ចូលក្នុងក្រុមរស់នៅបានមិនចាំបាច់សត្វព្រៃមានជាអាទិ៍គឺ មនុស្សដែលរស់នៅតាមទីក្រុងធំៗ អ្នកបច្ចេកទេសសំណង់ ឬបច្ចេកវិជ្ជាទំនើបៗដូចជាអ្នកជំនាញអេឡិកត្រូនិក ជាដើម ។ល។ ក្រុមមនុស្សនេះរស់នៅដោយទទួលទាន និងប្រើប្រាស់ផលិតផលភាគច្រើនដែលមានប្រភពមិនមែនសត្វព្រៃ។ រីឯក្រុមមនុស្សដែលអាចរស់នៅបានដោយចាំបាច់សត្វព្រៃដូចជា ក្រុមអ្នករស់នៅតាមតំបន់ជន បទស្រុកស្រែក្បែរតំបន់ព្រៃនៃភូមិភាគឥសាន ជួរភ្នំដងរែក និងតំបន់ជួរភ្នំក្រវាញ ។ ក្រៅពីក្រុមទាំងពីរខាងលើមានក្រុមមនុស្សមួយក្រុមទៀតដែលមានទំនាក់ទំនងដោយប្រយោលជាមួយនឹងសត្វព្រៃគឺក្រុមអ្នកធ្វើការគ្រប់គ្រងធនធានសត្វព្រៃ ។ ក្រុមចុងក្រោយនេះ មានសារៈសំខាន់ណាស់ដល់ចីរភាពវត្តមាននៃធនធានសត្វព្រៃ ព្រោះពួកគេជាអ្នកធ្វើសេចក្តីសំរេចលើការចាត់ចែងនិងថែរក្សាធនធានសត្វព្រៃ ។ ក្រុមទាំងពីរនោះនៅកម្ពុជាគឺ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផល) និងក្រសួងបរិស្ថាន (អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធនធានធម្មជាតិ)។ ក្រៅពីនេះនៅមានក្រុមមនុស្សដែលបំរើការឱ្យអង្គការអភិរក្សធនធានធម្មជាតិ ឬការប្រើប្រាស់ធនធានធម្មជាតិមួយចំនួនទៀតផងដែរ ។

## ១.១ ការប្រមើលមើលអំពីមនុស្សបឋម

មនុស្សបានចាប់មានអត្ថិភាព[១] ជាសត្វព្រៃមួយប្រភេទ និងការរស់នៅរបៀបជាសត្វ ព្រមទាំងមានការនិយមចូលចិត្តជាមួយនឹងប្រភេទសត្វនានានៅជុំវិញខ្លួន ។ មិនខុសពីពេលបច្ចុប្បន្ននេះទេ មនុស្សបុរាណបានធ្វើការអង្កេត និងរៀនពីអ្វីៗ (បរិស្ថាន) ដែលនៅជុំវិញខ្លួនគេ ។ មនុស្សបុរាណបានធ្វើការតស៊ូប្រជែងរកចំណីជាមួយនឹងប្រភេទសត្វដទៃ តស៊ូការពារខ្លួនប្រឆាំង ឬប្រយុទ្ធជាមួយប្រភេទសត្វដទៃទៀតដើម្បីការពារខ្លួន និងព្យាយាមទាញយកផលពីដំណើរធម្មជាតិដើម្បីឱ្យខ្លួនឯងក្លាយជាប្រភេទ "**លប់**" លើប្រភេទសត្វដទៃ ។ ដោយសារការវិវត្តន៍នៃខួរក្បាល អវយវៈ (អំណោយទានជើងមុខក្លាយជាដៃ) និងការពិចារណានាំឱ្យមនុស្សមានលទ្ធភាពកសាង (សាងសង់) ឧបករណ៍ប្រើប្រាស់ និងអាវុធសំរាប់បំរើបំរាស់ក្នុងជីវភាពប្រចាំថ្ងៃ ។ ដោយសារការវិវត្តន៍នេះដែរ មនុស្សអាចបង្កើតភាសាដើម្បីប្រាស្រ័យទាក់ទងគ្នា និងបន្តផ្តល់ចំណេះដឹង ឬបទពិសោធន៍ដែលខ្លួនបានជួបប្រទះពីជំនាន់មួយទៅមួយទៀតផង ។

ការវិវត្តន៍ពីប្រភេទត្រកូលពានរជាតិ ដើម្បីក្លាយបានជា "មនុស្ស" រាប់រយពាន់ (រាប់សិបម៉ឺន) ឆ្នាំនៅក្នុងស័ក្ក **ប្លេសតូសែន** (Pleistocene) ហាក់ដូចជាយូរណាស់ បើយើងមើលពីសតវត្សយើងនេះ ប៉ុន្តែវាហាក់ដូចជាឆាប់ណាស់បើធៀបទៅនឹងការវិវត្តន៍របស់ប្រភេទសត្វដទៃទៀតរាប់ស័ក្ក ។

តាមការស្រាវជ្រាវបង្ហាញថា មនុស្សដំបូងគេបានចាប់ផ្តើមកកើតឡើងនៅទ្វីបអាហ្វ្រិក ។ ក្នុងចំណោមប្រភេទសត្វព្រៃដទៃទៀត ដែលមកកកកុញផ្តុំគ្នានៅតំបន់មាត់ទឹកនៅរដូវរាំងស្ងួតម្តងៗ មនុស្សបានឆ្លៀតយកបញ្ញារបស់ខ្លួនមកប្រើដើម្បីសំលាប់ប្រភេទសត្វដទៃ ឬយកសាច់សត្វដែលងាប់ស្រាប់ជាអាហារ ។ ដោយសារនៅតំបន់ត្រូពិកក្នុងស័ក្កប្លេសតូសែនមានកើតភ្លើងមុនតំបន់ដទៃ ព្រោះមានផ្លេកបន្ទោរ មនុស្សក៏បានប្រើប្រាស់ភ្លើងជាមធ្យោបាយដុតរុក្ខជាតិឈើឱ្យ

---

[១] អត្ថិភាព គឺភាពមានជាអ្វីមួយ សភាវៈវត្តមាន (ឧ. អត្ថិភាពជាទន្សាយគល់)

ងាប់ដើម្បីបង្កើតវាលស្មៅ ដែលនៅទីនោះទាក់ទាញសត្វតិណាសី (សត្វស៊ីស្មៅជាអាហារ) រួចប្រមាញ់សត្វទាំងនោះជាអាហារ ។

ប្រហែលរាប់រយពាន់ឆ្នាំ បុព្វមនុស្សបានមានមុខងារជាអ្នករុករកអាហារដោយផ្អែកលើអ្វីដែលអាចរកបាន (អាចមាន) ដោយបរិភោគអាហារគ្រប់មុខ (សព្វាសី - omnivorous) ។ ជាបន្តបន្ទាប់មកមនុស្សបានបង្កើតឧបករណ៍ថ្មីៗដូចជា ព្រួញ លំពែងថ្ម ដំបង ។ល។ ដើម្បីប្រមាញ់សត្វព្រៃជាអាហារ (រូប ១) ។ លើសពីនេះទៀត មនុស្សបានបង្កើតកំលាំងមួយដែលគ្មានប្រៀបនៅពេលនោះ គឺការប្រមាញ់ជាក្រុម ។ ដោយសារកត្តាល្អៗទាំងនេះ មនុស្សអាចប្រជែងរស់ឈ្នះលើប្រភេទមំសាសត្វ (សត្វស៊ីសាច់ជាអាហារ) ដូចជា គោ ឆ្កែព្រៃ ។ល។ ឬសត្វសព្វាសីដទៃទៀតនៅក្នុងសហគមន៍សត្វទាំងអស់របស់គេដូចជាខ្លាឃ្មុំ ។ គួរបញ្ជាក់ផងដែរថា ដោយសារការប្រជែងរស់បែបនេះក៏មានប្រភេទសត្វមាឌធំខ្លះៗបានរលត់ផុតពូជនៅពេលនោះ ។

នៅក្នុងរយៈពេលស្វែងរកអាហារ មនុស្សសំឡឹងឃើញសត្វព្រៃជាវត្ថុចាំបាច់បំផុតសំរាប់ជីវភាពរបស់គេ ។ គេបានយល់ថាសត្វព្រៃជាអាហារ ជាគូប្រជែងក្នុងជីវភាព និងជាសត្រូវ ។ តឹកតាងបញ្ជាក់ពីអត្ថន័យនេះគឺមានបង្ហាញនៅតាមផ្ទាំងចំលាក់ក្នុងរូងថ្មនានា ដែលនៅទីនោះមនុស្សបានស្នាក់នៅដូចជាក្នុងរូងភ្នំ ផ្ទាំងថ្មនៃទ្វីបអាហ្វ្រិក និងអឺរ៉ុប (រូប ២) ។

ក្រោយមកដោយមានការធ្វើពាហនកម្មសត្វព្រៃ គេបានដឹងថាឆ្កែគឺជាប្រភេទសត្វទី ១ ដែលបានក្លាយជាសត្វស្រុក ព្រោះគេអាចបង្កើរវាបានក្នុងដំណើរប្រចាំជីវភាពរបស់គេ ។ បន្ទាប់ពីឆ្កែមានជ្រូក ប្រភេទសត្វស្លាប (មាន់) អំបូរគោសាទិស (គោ-ក្របី) ចៀម ពពែ និងសេះ ។ ពពួកសត្វដែលបានធ្វើពាហនកម្មចុងក្រោយនេះ (គោ-ក្របី ចៀម ពពែ សេះ) មិនមែនត្រូវបានគេចិញ្ចឹមតែ ១ ឬ ២ក្បាលដូចពពួកឆ្កែទេ តែគេបានចិញ្ចឹមវាទាំងហ្វូងៗ រួចឃ្វាលឱ្យស៊ីស្មៅលើទីវាលធំៗពីកន្លែង ១ ទៅកន្លែង ១ទៀត ជាដំណើរពនេចរ (nomadic) ផង ។

រូប ១ : ថ្មប្រមាញ់



រូប ១ : គំនូសសត្វព្រៃក្នុងរូងមនុស្សបឋម



ដកស្រង់ពី John H Relethford ២០០០

## ១.២ ប្រវត្តិ

ការប្រជែងរស់មានជាបន្តបន្ទាប់ចំពោះរាល់ប្រភេទសត្វព្រៃ ។ ជាលទ្ធផល និងដោយមានឥទ្ធិពលប្រែប្រួលបរិស្ថាន ប្រភេទសត្វមួយចំនួនបានបាត់ទៅវិញ ហើយខ្លះទៀតបានកើតឡើងវិញបន្តបន្ទាប់ដែរ ។ ក្រោយពីភាពរីកចំរើនរបស់មនុស្ស មនុស្សបាន និងកំពុងប្រជែងរស់ក្នុងចំណោមប្រភេទសត្វព្រៃដទៃៗទៀត ។ ដោយសារសកម្មភាពមួយចំនួនរបស់មនុស្សបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ភាពរីកចំរើន ឬថយចុះរបស់សត្វព្រៃ ។ ឆ្លងតាមការកត់ត្រា គេឃើញមានហេតុសំខាន់ៗចំនួន ២ ដែលនាំឱ្យសត្វព្រៃថយចុះគឺ ដោយសារទំនើបកម្មកសិកម្ម និងទំនើបកម្មសង្គម ។

### ១.២.ក ទំនើបកម្មកសិកម្ម

មនុស្សបានរកឃើញវិធីថ្មីៗដើម្បីបង្កើនទិន្នផលកសិកម្មរបស់ខ្លួន ។ ទន្ទឹមនេះ មនុស្សក៏ទាមទារកសិផលឱ្យកើនឡើងច្រើនដែរ ហេតុនេះគេ (មនុស្ស) ក៏រកវិធានថ្មីៗដើម្បីត្រួតត្រាលើផ្ទៃដីមួយសមស្របទប់ទល់នឹងការប្រើប្រាស់របស់សត្វព្រៃដទៃៗទៀត ។ លើសពីនេះទៀតទំនើបកម្មកសិកម្មរបស់មនុស្សក៏ត្រូវបាន និងកំពុងត្រូវបានបង្កើនឡើងជាបន្តបន្ទាប់ ។ មនុស្សទាមទារការគ្រប់គ្រងផ្ទៃដីធំទូលាយមួយសមស្របដើម្បីដាំដំណាំ ហើយការទាមទារនេះនាំឱ្យមានការប្រឆាំងនឹងការបំផ្លាញរបស់សត្វព្រៃ ដូចជា ការការពារសត្វពាហនៈពីពពួកមំសាសី (ខ្លា ចចក ឆ្កែព្រៃ) ឬការពារដំណាំពីការស៊ី ការដើរជាន់របស់ពពួកតិណាសី (ដំរី រមាំង ។ល។)

តំបន់ព្រៃឈើជាទីតាំងរបស់សត្រូវរបស់មនុស្ស ហេតុនេះនាំឱ្យមនុស្សព្យាយាមជំរះ កាប់ឆ្ការព្រៃឱ្យអស់ច្រើនដែលអាចធ្វើបាន ដោយប្រើប្រាស់ភ្លើង និងកាំបិតពូថៅ ។ តែការប្រឹងប្រែងរបស់មនុស្សពេលនោះមិនទាន់ឈ្នះ "ពពួកព្រៃ" (សត្វព្រៃ និងរុក្ខជាតិព្រៃ) ដែលចេះតែវានត្រឡប់មករកមនុស្សវិញនៅឡើយទេ ។ ហេតុនេះ ពេលដែលល្អ មនុស្សឈ្នះពពួកសត្វ (ដុតព្រៃ និងសំលាប់សត្វព្រៃ) តែដល់ពេលណាមួយនោះសត្វព្រៃសាហាវទាំងនោះវានមកកន្លែងចាស់ (ដើម) របស់វាវិញ ។ ព្រៃឈើដុះលើដីចំការ និងស្រែចាស់ ហើយបញ្ហាដែលមនុស្សជួបប្រទះគឺ

ការកាប់ឆ្ការព្រៃ និងប្រយុទ្ធជាមួយពពួកសត្វព្រៃសាហាវដែលសាយកូនមកនៅជិតៗផ្ទះ ឬភូមិរបស់ពួកគេ។ ដោយសារទំនើបកម្មកសិកម្ម ផ្ទៃដីព្រៃដ៏ធំល្វឹងល្វើយត្រូវបានប្រែក្លាយជាវាលស្រែចំការ អចិន្ត្រៃយ៍ ។

### ១.២.៤ ទំនើបកម្មសង្គម

គ្រួសាររាជវង្ស (ស្តេច) អធិរាជ ឬអភិជនបានចំណាយពេលវេលាដែលនៅសល់ពីការងារស្នូលរបស់ពួកគេទៅធ្វើការប្រមាញ់ជាលក្ខណៈកីឡា ។ ដោយមានបុព្វសិទ្ធិ ឬការបែងចែកវណ្ណៈភាពក្នុងសង្គមជាបន្តបន្ទាប់ក្រុមគ្រួសារទាំងនោះបានបង្កើតតំបន់ប្រមាញ់កីឡាពិសេសសំរាប់តែពួកគេដោយមិនអនុញ្ញាតឱ្យជនសាមញ្ញទទួលផល-អនុផលពីព្រៃឬសត្វព្រៃនៃតំបន់នោះឡើយ។ វិធានការបែបនេះនាំឱ្យមានបដិវត្តដីធ្លី ហើយជាលទ្ធផលកសិកម្មកាប់ឆ្ការព្រៃ (កសិកម្មពនេចរ) ឬសំលាប់សត្វព្រៃនៅក្នុងតំបន់ដែលស្តេចបានការពារ ឬឃាត់ឃាំងកន្លងមកនោះ ។

ផ្ទុយមកវិញ ដោយឃើញការហិនហោច និងបាត់ពូជប្រភេទសត្វព្រៃជាបណ្តើរៗ ស្តេច (ភាគច្រើន) បានដើរតួមុខគេបង្កើតកម្មវិធីអភិរក្សដូចជា តំបន់ការពារ ឬឧទ្យានជាតិ ឬដែនជម្រកសត្វព្រៃ ។ល។ សកម្មភាពអភិរក្សទាំងនេះកន្លងមកក៏បានផ្តើមគំនិតឱ្យមានឡើងនៅក្នុងបណ្តាប្រទេសក្រោមអាណានិគម ឬប្រទេសទើបរំដោះផុតពីនឹមអាណានិគមខ្លះៗដែរ នៅពេលប្រមាណជា ៥០ ទៅ ១០០ឆ្នាំ កន្លងមកនេះ ។ តម្លៃនៃសត្វព្រៃចំពោះជីវភាពនៅតែបន្ត ហើយចំពោះការអភិរក្សកាន់តែត្រូវបានរដ្ឋាភិបាលនៃប្រទេសជាច្រើនបាន និងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាដែរ ។

## ១.៣ តម្លៃសត្វព្រៃ

តម្លៃសត្វព្រៃអាចជា "តម្លៃផ្ទាល់" ឬ "តម្លៃមិនផ្ទាល់" ។ តម្លៃផ្ទាល់នៃសត្វព្រៃមានដូចជាសំរាប់ជីវភាពមនុស្ស (អាហារ គ្រឿងតែងលំអ និងទំនិញ) រីឯតម្លៃប្រយោល (មិនផ្ទាល់) មានដូចជាសំរាប់សោភ័ណ្ឌភាព ទេសចរណ៍ វប្បធម៌ និងវិទ្យាសាស្ត្រ ។

### ១.៧.១ តម្លៃផ្ទាល់ ( តម្លៃពាណិជ្ជកម្ម ឬទំនិញ)

ក) សាច់ (ជាតិប្រូតេអ៊ីន): សត្វព្រៃបន្តផ្តល់សាច់ដល់ការរស់នៅរបស់មនុស្សរហូតមក និងទៅអនាគត ។ តាមការស្រាវជ្រាវបានឱ្យដឹងថា មនុស្សបានចាប់ផ្តើមបរិភោគសាច់សត្វ (ជាតិប្រូតេអ៊ីន) កាន់តែច្រើនឡើងៗបន្ទាប់ពីគេបានរកឃើញ "ភ្លើង" មក (រាប់ពាន់ឆ្នាំកន្លងមក) ។ ការបរិភោគជាតិប្រូតេអ៊ីនបានជួយឱ្យមនុស្សមានប្រាជ្ញាកាន់តែវៃឆ្លាតឡើងៗ ។ ដើមឡើយគេបានរុករកសត្វ ដែលមានមាឌតូចៗ ដូចជាត្រី ថនិកសត្វតូចៗ និងបក្សីជាច្រើនប្រភេទទៀត ព្រោះសមត្ថភាពរបស់មនុស្សកាលនោះនៅមានកំរិតទាបនៅឡើយ ។ ដោយសារគំនិតច្នៃប្រឌិតរបស់មនុស្សកាន់តែវិវឌ្ឍន៍ឈានឡើង ហើយសេចក្តីទាមទារក្នុងជីវភាពកាន់តែខ្ពស់ឡើងៗនាំឱ្យការប្រមូលផលសត្វព្រៃកាន់តែធំធេងឡើងៗដែរ ។ ព្រមពេលនោះ ការប្រើប្រាស់ឧបករណ៍ក៏កាន់តែទំនើបឡើងជាលំដាប់ ដែលនាំឱ្យការវិនាសហិនហោចដល់ធនធានសត្វព្រៃក៏កាន់តែឆាប់រហ័សណាស់ដែរ ។

ដើមឡើយមនុស្សបានប្រើប្រាស់ឧបករណ៍ងាយៗជាទីបំផុតដូចជាអន្ទាក់ ស្នា ធ្នូ និងឆ្កែជាដើម ដើម្បីប្រមាញ់សត្វព្រៃមកធ្វើជាម្ហូបអាហារ ។ រហូតមកដល់ពេលប្រមាណជាង ៣០ឆ្នាំកន្លងមកនេះទៀតនៅកម្ពុជា ប្រជាពលរដ្ឋបានបន្តប្រើប្រាស់ឧបករណ៍ងាយៗទាំងនោះផងដែរ ។ ការប្រើប្រាស់ឧបករណ៍ងាយៗទាំងនេះ ហើយដែលអាចជាគុណប្រយោជន៍មួយដល់ការធានាការបន្តផ្តល់ផលរបស់សត្វព្រៃផងទាំងពួង ។ យើងអាចពិនិត្យមើលផលសត្វព្រៃ ដែលគេអាចរកបាននៅក្បែរៗភូមិកាលពី ២០ឆ្នាំមុននេះ តែមកទល់ពេលនេះ ប្រជាពលរដ្ឋទាំងអស់គ្នាពោលពាក្យថាមិនសូវមានសត្វព្រៃនៅក្បែរភូមិ ឬពិបាករកត្រីបន្ទាប់ពីឧបករណ៍នេសាទកាន់តែទំនើបទៅៗ ព្រមទាំងមិនសូវមានការគោរពច្បាប់នេសាទ ។ ពពួកសត្វព្រៃក៏មិនខុសគ្នាពីត្រីដែរគឺការប្រើប្រាស់អាវុធស្វ័យប្រវត្តិនាំឱ្យវិនាសធនធានសត្វព្រៃនៅកម្ពុជា ។

ខ) ស្បែក ឆ្អឹង: សត្វជាច្រើនប្រភេទបាន និងកំពុងផ្តល់ ស្បែក ឆ្អឹង និងសរីរៈជាច្រើនទៀតនៃដងខ្លួនរបស់វាចំពោះមនុស្សសំរាប់ជាវត្ថុធាតុដើមផលិតឱសថព្យាបាលជម្ងឺ ។ សារៈសំខាន់ទាំងនេះរបស់សត្វព្រៃបានថែបំប៉នសុខភាពរបស់មនុស្សគ្រប់សញ្ជាតិតាំងពីរាប់ម៉ឺនឆ្នាំមកហើយ ។ ទោះបីការរកឃើញឱសថសម័យ ដែលមានប្រសិទ្ធិភាពយ៉ាងខ្ពស់ដូចបច្ចុប្បន្នកាលនេះហើយក៏ដោយ ក៏ស្បែក ឆ្អឹង ទាំងនេះនៅតែមានអត្ថប្រយោជន៏ដល់ការព្យាបាលជម្ងឺរបស់ប្រជាពលរដ្ឋជនបទដដែល ។ ចំពោះជម្ងឺខ្លះទៀត ឱសថសម័យមិនអាចព្យាបាលបានផង ពិសេសបងប្អូននៅតាមជនបទដែលធ្លាប់បានប្រើប្រាស់ថ្នាំបុរាណព្យាបាលជម្ងឺមួយចំនួនរបស់គេហើយនោះ ។ ពិសេសទៅទៀតនោះ ឱសថបុរាណដែលមានដើមកំណើតមកពីធនធានសត្វព្រៃនេះមានតម្លៃថោកសមល្មមចំពោះជីវភាពរបស់ពួកគេក្នុងជីវភាពប្រចាំថ្ងៃ ។ ពួកគេពិបាកណាស់នឹងរកប្រាក់ទិញថ្នាំសម័យ តែមានភាពងាយស្រួលបើពួកគេប្រើប្រាស់ឱសថបុរាណ ។ យើងមានជំនឿទុកចិត្តថា សត្វព្រៃនឹងនៅតែបន្តតាមបំរើប្រជាពលរដ្ឋយើងទៀត បើពួកគេចេះ ឬគោរពច្បាប់ក្នុងការដកហូតធនធានរបស់គេនេះមកប្រើឱ្យបានសមស្របតាមលទ្ធភាពលូតលាស់ និងផ្តល់ផលរបស់សត្វព្រៃ ។

សត្វព្រៃនៅកម្ពុជាផ្តល់តម្លៃពាណិជ្ជកម្មដូចជា ភ្លុក ស្នែងទន់ (ឬស្នែងរឹង) ស្បែក និងឆ្អឹងខ្លា និងសាច់សំរាប់ជាអាហារ ។ ភ្លុកដំរីរាប់ម៉ឺនតោនត្រូវគេដឹកចេញពីកម្ពុជានៅរយៈពេលនៃឆ្នាំ ១៨៦៣-១៩៥៤ (ឯកសារ ONF ឆ្នាំ ២00៤ ហ៊ាន ឈាង ឆ្នាំ ១៩៩៦ Institut, ១៩៧0) ។ ស្បែក និងឆ្អឹងខ្លាដំបង និងខ្លាដទៃទៀតត្រូវបានឈ្មួញប្រមូលទិញពីកម្ពុជា និងប្រទេសក្នុងតំបន់រហូតដល់ទសវត្សឆ្នាំ ១៩៩0 ។ គេឃើញមានផលិតផលអំពីសត្វខ្លាខ្លះៗទៀតបានត្រូវគេធ្វើពាណិជ្ជកម្មនៅក្នុងអំឡុងដើមទសវត្សឆ្នាំ ២000 ។ តម្លៃរាប់សិបលានដុល្លាសហរដ្ឋអាមេរិកត្រូវបានគេទទួលបានពីជំនួញសត្វព្រៃ និងផលិតផលខ្លាទាំងនេះ ។ ដោយសារជំនួញគ្មានប្រណីនាំឱ្យសត្វទាំងនេះផុត ឬស្ទើរផុតពូជ ហើយខ្លះទៀតឈានទៅរកផុតពូជពីទឹកដីកម្ពុជា ឬភូមិភាគខ្លះនៃសកលលោក ។ នៅពេលបច្ចុប្បន្ននេះភ្លុកដំរី ឬកុយរមាសបាន និងកំពុងត្រូវគេ

ធ្វើពាណិជ្ជកម្មនៅក្នុងទ្វីបអាហ្វ្រិក ឬនាំចេញទៅក្រៅទ្វីបនេះ ។ ទីផ្សារភ្លុក ឬកុយធំជាងគេគួរកត់សំគាល់នៅលើសកលលោកនាពេលនេះគឺ ប្រទេសចិន ជប៉ុន ឬកូរ៉េ ។ ភ្លុកដំរីអាស៊ីក៏រងការធ្វើពាណិជ្ជកម្មដែរ នៅពេលនេះ ពិសេសនៅប្រទេសឥណ្ឌា និងស្រីលង្កា ។ ភ្លុកដំរីកម្ពុជាបានត្រូវឃើញជាចំណូលថវិកាជាតិកម្ពុជាយ៉ាងខ្ពស់នៅអំឡុងឆ្នាំ ១៩៥០ ដល់ ១៩៩០ ។ ដោយឡែកប្រភេទសត្វព្រៃមួយចំនួនទៀតដូចជា ពង្រូល ភេ អណ្តើក កន្ធាយ សាច់សត្វព្រៃគ្រប់ប្រភេទក៏មានតម្លៃពាណិជ្ជកម្មដោយផ្ទាល់ដែរ ។

ភ្លុកដំរី កុយរមាស និងស្បែក-ឆ្អឹងខ្លា ក៏បាន និងកំពុងត្រូវគេធ្វើពាណិជ្ជកម្មនៅលើសកលលោកដែរ បើទោះបីដោយស្រប ឬដោយខុសច្បាប់ក្តី ហើយប្រភេទសត្វព្រៃទាំងនេះកំពុងទទួលការគំរាមកំហែងជិតផុតពូជ ។

គ) ការលក់ផលសត្វព្រៃ: នៅពេលអនាគត សត្វព្រៃរស់អាចនឹងដាក់លក់ ។ បណ្តាប្រទេសជាច្រើនមានប្រទេសអាហ្វ្រិកខាងត្បូង ជាដើម សត្វព្រៃសំបូរលើសលប់ក្រោយពីគេបានថែរក្សាវាដោយហ្មត់ចត់ ។ សត្វទាំងនោះគ្មានចំណី (ស្មៅ) ផ្គត់ផ្គង់ត្រូវគេនាំយកទៅដាក់លក់ជាសាធារណៈ ឬលក់ឱ្យបណ្តាសួនសត្វដទៃទៀត ។ គួរកត់សំគាល់ដែរថាមុននឹងយកទៅលក់សត្វព្រៃទាំងនោះត្រូវបានគេយកចំណេញជាច្រើនពីវាដោយយកកម្រៃពីអ្នកទេសចរដែលមកទស្សនា ។

### ១.៣.២ តម្លៃប្រយោល

ក) ការរក្សាលំនឹងជីវចំរុះ: ការរស់រានមានជីវិតប្រចាំថ្ងៃបានគឺដោយសារមានការគាំទ្រពីមជ្ឈដ្ឋានខាងក្រៅ ។ មជ្ឈដ្ឋានខាងក្រៅនោះជាអាទិ៍មានខ្យល់ ទឹក កំដៅថ្ងៃ និងចំណីអាហារ ។ ចំណីអាហាររបស់មនុស្សគឺមានប្រភពពីធនធានធម្មជាតិ ដែលរួមបញ្ចូលទាំង បន្លែ (ស្លឹក មើម ដើមរុក្ខជាតិ) សាច់ (ជាតិប្រូតេអ៊ីន) និងគ្រាប់ធញ្ញជាតិជាច្រើនទៀត ។ នៅក្នុងក្រិតក្រមធម្មជាតិ ការពឹងពាក់អាស្រ័យគ្នាទៅវិញទៅមករវាងកត្តាមនុស្ស សត្វ និងរុក្ខជាតិ គឺមានចំណងពាក់ព័ន្ធគ្នាមិនអាចកាត់ផ្តាច់បានឡើយ ហើយបើមានការផ្តាច់ណាមួយហើយនោះលោកនេះនឹងនាំឱ្យ

មានការវិវត្តន៍ឈានទៅរកអ្វីមួយផ្សេងទៀតជាពុំខាន ។ គឺបណ្តុំនេះហើយ ដែលរក្សាលំនឹងជីវចំរុះ ហើយការរក្សាបានលំនឹងនេះហើយដែលអាចឱ្យប្រភេទសត្វ រុក្ខជាតិនានារស់រានមានជីវិត និងធំធាត់ ។ ជាឧទាហរណ៍ មនុស្សអាចទទួលបានផាសុខភាពក្នុងជីវភាពប្រចាំថ្ងៃគឺដោយសារការបង្កឱ្យមានភាពសមស្របមួយនៃធាតុអាកាស ។ នោះគឺ សីតុណ្ហភាពមួយសមស្រប (២៥-៣៧អង្សាសេ) មានរដូវកាលទៀងទាត់ ចំណីអាហារគ្រប់គ្រាន់ និងភាពគ្មានជម្ងឺបៀតបៀនធ្ងន់ធ្ងរ ។

<u>ខ) ការរក្សាលំនឹងបរិស្ថានៈ</u> បរិស្ថានសមស្របស្ថាបនាភាពរុងរឿងក្នុងជីវិត ។ ការរស់នៅក្នុងបរិស្ថានមួយសមស្រប គឺការរស់នៅក្នុងមជ្ឈដ្ឋានមួយដែលមិនក្តៅពេក មិនស្ងួតពេក មិនភ្លៀងពេក និងមិនមានទឹកជំនន់ញឹកញាប់ពេក ។ ដើម្បីឱ្យមានបរិស្ថានបែបនេះមួយបានលុះត្រាណាតែសមាសភាគនានានៃបណ្តុំបរិស្ថានត្រូវបានគេធានាឱ្យដំណើរការជាប្រក្រតីតាមមុខងាររបស់វារៀងៗខ្លួន ។ នោះគឺការរក្សាដំណើរលូតលាស់របស់ព្រៃឈើ ការបន្តពូជពង្សរបស់សត្វព្រៃនិងមនុស្ស និងការរក្សាសភាពប្រក្រតីនៃក្រឹតក្រមរបស់ធនធានអជីវៈ (Abiotic resource) ដូចជាភ្លៀង ខ្យល់ ដី និងគុណភាពរបស់វាជាដើម ។

រក្សាខួបផ្តល់ផលៈ សត្វព្រៃមានលទ្ធភាពបង្កើតកូនតាមចំនួនកំណត់របស់វាទៅតាមពូជនិងរដូវកាលរបស់វា ។ លទ្ធភាពផ្តល់ផលតាមខួបនេះហើយហៅថា "ខួបផ្តល់ផល" ។ បើយើងចេះដកហូតយកតែចំនួនកំណត់នោះ យើងនឹងអាចរក្សាខួបផ្តល់ផលរបស់សត្វព្រៃរបស់យើងពីជំនាន់មួយទៅមួយទៀត ។ យើងអាចប្រៀបប្រដូចការដកហូតយកផលនេះទៅនឹងការដាក់ប្រាក់ឱ្យគេចងការ ។ ម្ចាស់ប្រាក់មិនយកប្រាក់ដើមរបស់ខ្លួនទៅចាយទេ ប៉ុន្តែគេចាយប្រាក់កាសដែលបានមកពីអ្នកខ្ចីប្រាក់ ហើយម្ចាស់នោះនឹងនៅតែមានលុយចាយតរៀងទៅ ។ ហេតុនេះហើយដែលយើងចង់បានការរក្សាខួបផ្តល់ផលនេះ ។

<u>គ) កម្លាំងដឹកជញ្ជូនៈ</u> សិលាចារិកបានឱ្យយើងដឹងថា ដំរីព្រៃត្រូវបានមហាបុរសកម្ពុជាទាក់យកមកប្រើប្រាស់តាំងពីមុនសម័យមហានគរ និងក្នុងសករាជមហានគរមកម្ល៉េះ (Chisto-

pher Pym, 1968 ទំព័រ ១៥១) ។ សិលាចារិកបានបញ្ជាក់ច្បាស់ទៀតថា ដំរីស្រុកបានបំរើជាមធ្យោបាយដឹកជញ្ជូនយ៉ាងសំខាន់ពីមហានគរកម្ពុជាទៅនគរចំប៉ា ។

រហូតមកដល់សម័យសង្គមរាស្ត្រនិយម (១៩៧០) ដំរីស្រុកនៅតែត្រូវបានប្រជាពលរដ្ឋកម្ពុជា ពិសេស នៅតាមតំបន់ជនបទ ប្រើប្រាស់ដើម្បីដឹកជញ្ជូនផល អនុផលកសិកម្ម ឬឱសថបុរាណ ពីភូមិមួយទៅភូមិមួយទៀត ។ សូរសំលេងស្នែងបានដាស់អារម្មណ៍អ្នកស្រុក អ្នកភូមិទាំងអស់ឱ្យដឹងថា ដំរីស្រុកមកដល់ភូមិរបស់គេទៀតហើយ ។ នោះគឺដំរីដែលបន្តពីជំនាន់មួយទៅមួយទៀត ដឹក ឱសថបុរាណសំរាប់ព្យាបាលមនុស្សរាប់លាននាក់តាំងពីបុរាណកាលមក ។ ដំរីស្រុកលក់ឱសថបុរាណបែបនេះធ្វើដំណើរឆ្លងពីត្រើយម្ខាងទៅត្រើយម្ខាងទៀតនៃប្រទេសដោយហ្មដំរីមិនសូវ មានក្តីបារម្ភពីការស្ទះចរាចរឬជាប់ផុងសោះឡើយ ។ ហ្ម និងដំរីរបស់គេធ្វើដំណើរកាត់ព្រៃភ្នំក្រំថ្ម និងលើផ្លូវថ្នល់ដោយគ្មានឧបស័គ្គអ្វីសោះឡើយ ។

រហូតដល់អំឡុងឆ្នាំ ២០០០ បងប្អូនប្រជាពលរដ្ឋ ពិសេសនៅតាមតំបន់ភូមិភាគឥសានបានប្រើប្រាស់ដំរីស្រុកធ្វើជាយានជំនិះជាមធ្យោបាយដឹកជញ្ជូន និងអូសទាញយ៉ាងចាំបាច់បំផុតសំរាប់ជីវភាពប្រចាំថ្ងៃរបស់គេ ។ បងប្អូនជនជាតិនៅក្នុងភូមិភាគឥសានទទួលស្គាល់ថា "គ្រួសារណាមានដំរីស្រុកគ្រួសារនោះជាអ្នកមានជាងគេនៅក្នុងភូមិ" ។ ចំពោះខេត្តមណ្ឌលគិរី ពួកគេឱ្យតម្លៃនៃការប្រើប្រាស់ដំរីស្រុកស្មើនឹងរថយន្តកុំម៉ង់ការរបស់អតីតសហភាពសូវៀត (Russian Jeep) ។ តាមការសួរយោបល់ពីហ្មដំរីមួយចំនួនក្នុងខេត្តនេះបានឱ្យដឹងថាដំរីស្រុករបស់ពួកគាត់អាចផ្ទុកទំងន់បានពី ៥០០ ទៅ ១០០០ គីឡូក្រាម ហើយអាចឱ្យធ្វើដំណើរក្នុងទំងន់នេះអំឡុងពេលមួយសប្តាហ៍ ។ ការដឹកទំនិញនេះទៀតសោត ដំរីស្រុកមិនចាំបាច់ផ្លូវថ្នល់ដើម្បីធ្វើដំណើរទេ គឺដំរីអាចដើរកាត់ព្រៃ ឬវាល ស្រែបានយ៉ាងងាយ ។

ឃ) <u>ការដាក់តាំងលំអៈ</u> ក្រៅពីផ្កា រុក្ខជាតិតុម្តតូចៗ និងវត្ថុតាំងលំអជាច្រើនទៀត សំណាកសត្វព្រៃក៏គឺជាវត្ថុសិល្បៈមួយដ៏សំខាន់សំរាប់ការតាំងលំអផ្ទះសម្បែង និងមានការនិយមជាច្រើនពីសំណាក់ប្រជាពលរដ្ឋទូទៅ ។ ប្រពៃណីនេះមានការប្រតិបត្តិតៗគ្នាមករហូតបច្ចុប្បន្ន

ទាំងនៅកម្ពុជា ទាំងនៅក្នុងបណ្ដាប្រទេសដទៃទៀតលើសកលលោក ។ សំណាកសត្វ ឬអវៈយវៈសត្វខ្លះទៀតត្រូវគេយកទៅធ្វើជាវត្ថុជាទីសក្ការៈសក្តិសិទ្ធិសំរាប់គោរពបូជាប្រចាំថ្ងៃ ហើយទទួលសេចក្តីសុខសមស្របទៀតផង ។

ង) ទេសចរណ៍: ទេសចរណ៍គឺជាវិស័យមួយដែលបណ្ដាប្រទេសនានាលើសកលលោកយកចិត្តទុកដាក់ពង្រឹងពង្រីក ដើម្បីទាញយកផលចំណេញ ។ គេយល់ឃើញថា បើទេសចរមកទស្សនាប្រទេសគេកាន់តែច្រើននោះការទាញយកចំណូលជាសាច់ប្រាក់ក៏កាន់តែច្រើនដែរ ។ ការទាញយកចំណូលពីវិស័យទេសចរណ៍គឺ គេអាចទទួលយកបានតាំងពីប្រាក់បង់ថ្លៃទិដ្ឋាការ ព្រលានយន្តហោះ តាក់ស៊ី សណ្ឋាគារ និងការទទួលទានអាហារ ។ អ្នកទេសចរក៏ជាកត្តាមួយជួយឱ្យចលនាសេដ្ឋកិច្ចមានដំណើរការជាអលជ្ជីដែរ ។ បច្ចុប្បន្ននេះទៀត មានការកើនឡើងនៃអ្នកទេសចរមួយបែប ដែលគេឱ្យឈ្មោះថា "ទេសចរធម្មជាតិ" ។ អ្នកទាំងនោះចំណាយពេលវេលា និងថវិការបស់ខ្លួនដើម្បីធ្វើដំណើរទស្សនាព្រៃព្រឹក្សាពីប្រទេសមួយទៅប្រទេសមួយ ឬពីតំបន់មួយទៅតំបន់មួយទៀត ។ ធម្មជាតិដែលគេចង់គយគន់ជាងគេនោះគឺសត្វព្រៃ និងតំបន់ទេសភាពធំល្វឹងល្វើយ ដែលមានលក្ខណៈរស់រវើក និងស្រស់បំព្រង ។

ច) កំចាត់សត្វចង្រៃនៃដំណាំកសិកម្ម: ចង្វាក់វិលជុំ និងខ្សែបណ្ដាញត្រួតត្រាគ្នាទៅវិញទៅមករវាងប្រភេទសត្វនានានៅលើភពផែនដីយើងនេះគឺជាចលនាមួយមិនអាចកាត់ផ្ដាច់បាន ។ ដំណាំស្រូវនៅកម្ពុជាមានការពឹងផ្អែកច្រើនណាស់ទៅលើការជួយជ្រោមជ្រែងពីសត្វដែលនៅជុំវិញស្រែចំការ ។ ជាឧទាហរណ៍ ពស់ថ្លាន់ (*Python reticulatus*) មៀម (ពួកនេះចាប់កណ្ដុរជាអាហារ) សត្វស្លាបទឹកដូចជា កុក ត្រដក់ (ដែលស៊ីក្តាមជាអាហារ) សត្វស្លាបស៊ីសត្វល្អិត (មានក្រាជាដើម) និងពពួកសត្វព្រៃមាឌធំដទៃទៀត ដែលផ្តល់កាកសំណល់ជាជីដល់ដីកសិកម្ម ។ម្យ៉ាងវិញទៀត យើងបានឃើញ និងជួបជាបណ្ដើរៗហើយថាការប្រើប្រាស់ជីគីមី (ដើម្បីបង្កើនគុណភាពដី ឬកំចាត់សត្វចង្រៃចំពោះដំណាំកសិកម្ម) តែងតែជួបឧបស័គ្គផ្សេងៗទៀតពីឥទ្ធិពលនៃជាតិគីមីនេះ ។ នោះគឺដីប្រែក្លាយជាដីខ្សោះជីជាតិ រីឯប្រភេទសត្វចង្រៃផ្សេងទៀតក៏អាចកើតមានដែរ ។

### ១.៣.៣ តម្លៃសោភ័ណ្ឌ និងប្រពៃណីជនជាតិដើមភាគតិច

អាល់ដូ ឡេអូប៉ូល បានលើកឡើងថា "តម្លៃរបស់មនុស្សក៏ដោយសារមានវត្តមានសត្វព្រៃផងដែរ" ។ ការនិយមទស្សនាសត្វព្រៃ (នៅសួនសត្វភ្នំតាម៉ៅ និងគីរីរម្យ) កាន់តែកើនឡើងក្នុងរយៈពេលនៃទសវត្សឆ្នាំ ២០០០ នេះ ។ ទេសចរនៅក្នុងស្រុក និងបរទេសនៅកម្ពុជាជួយសេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចគ្រួសារ ។

លោកដាសម៉ាន់សង្កត់ធ្ងន់ថានៅលើផែនដីនេះ បើគ្មានសត្វព្រៃនៅជាមួយទេអនាគតរបស់មនុស្សអាចនឹងមានរយៈពេលខ្លី និងប្រកបដោយភាពហឹង្សា ។ អន្តរអំពើទាំងភាពរីករាយ (ពឹងអាស្រ័យគ្នា) ទាំងភាពប្រឈមដាក់គ្នា (ការប្រជែងរស់) រវាងសត្វព្រៃ និងមនុស្សមានជាបន្តបន្ទាប់ ។ ការប្រជែងរស់រវាងប្រភេទនានា ពិសេសគឺមនុស្ស និងប្រភេទសត្វដទៃនាំឱ្យមានការរីកចំរើនទាំងបញ្ហា និងសំភារៈ ។

ការបន្សល់ទុកទីជម្រកព្រៃឈើសមស្របឱ្យសត្វព្រៃបន្តវត្តមាននៅលើផែនដីនេះក៏ជាការចាំបាច់ណាស់ ។ ការបន្សល់ទុកទីជម្រក-ព្រៃឈើនេះទៀតសោតអាចនឹងឱ្យគេចំណាយតិចជាងការចំណាយដើម្បីស្តារជម្រកសត្វព្រៃដែលបានបាត់បង់ទៅ ។ បទពិសោធន៍ជាច្រើនអំពីការអភិរក្សនៅលើសកលលោកបង្ហាញថាការស្តារឡើងវិញនូវទីជម្រកសត្វព្រៃដែលត្រូវបានខូចខាតដោយសារសកម្មភាពរបស់មនុស្សចំណាយថវិកាច្រើនយ៉ាងសន្ធឹកសន្ធាប់ ហើយប្រទេសខ្លះមិនអាចមានថវិកាសំរាប់ចំណាយការស្តារនេះទៀតផង ។

ទស្សនីយភាព: សត្វព្រៃគឺជាភាគមួយមិនអាចកាត់ផ្តាច់បានពីទេសភាពធម្មជាតិ ។ ប្រភេទសត្វព្រៃនានាជួយឱ្យតំបន់ទេសភាពមានលក្ខណៈរស់រវើក ។ ជាឧទាហរណ៍ ផ្ទាំងគំនូរមួយបានទទួលជោគជ័យលើសគេដោយសារក្នុងគំនូរនោះមានសត្វចាបមួយតូចទំលើមែកឫស្សី ។ ប្រធានបទបានដាក់ថា ចូរអ្នកគូររូបភាពតំបន់ទេសភាពមួយដែលមានលក្ខណៈស្ងាត់ជ្រងំ ។ ជាងគំនូរជាច្រើនបានគូររូបភាពដោយមានតែរុក្ខជាតិ និងសណ្ឋានភាពដីភ្នំ ទឹកហូរ និងវាលស្រែ ។ល។ ដោយគ្មានសត្វព្រៃសោះឡើយ ។ គំនូរមានសត្វស្លាបដែលបានទទួលជ័យលាភីនោះព្រោះមាន

ន័យថាគ្មាន "មនុស្ស" ហើយបើគ្មានមនុស្សគឺគ្មាន "ការរំខាន" ហើយបើគ្មានការរំខានគឺមានន័យថា "ស្ងាត់ជ្រងំ" ។ ការទទួលអារម្មណ៍រីករាយជាមួយនឹងការឱ្យចំណីសត្វព្រៃដែលសាំងក៏ជាសេចក្ដីរីករាយមួយទៀតរបស់មនុស្ស ។ យើងឃើញថាមនុស្សភាគច្រើន (ពិសេសក្មេងៗ) ឱ្យចំណីសត្វពេលពួកគេធ្វើដំណើរទស្សនាសួនសត្វ ។ រីឯនៅបណ្ដាប្រទេសជឿនលឿន ពួកគេមានការគោរពបទបញ្ជាបានល្អនៅក្នុងសួនកំសាន្ត បណ្ដាសត្វព្រៃជាច្រើនប្រភេទសាំងនឹងមនុស្ស ហើយសត្វទាំងនោះអាចមកចឹកចំណី ឬប្រលែងលេងដោយកិរិតណាមួយជាមួយមនុស្សផងដែរ។ អ្នកទេសចរជាច្រើន ពិសេសអ្នកទេសចរធម្មជាតិមានសេចក្ដីរីករាយណាស់ពេលគេបានឃើញសត្វ ខ្លា ដំរី ឬសត្វមាឌធំដទៃទៀតក្នុងពេលពួកគេធ្វើដំណើរក្នុងតំបន់ឧទ្យានជាតិ ឬតំបន់ការពារទេសភាពនានា ។ អ្នកទាំងនោះចំណាយថវិកាជាច្រើន ដើម្បីធ្វើដំណើរទៅទស្សនាឧទ្យានជាតិជីត្វាន ប្រទេសណេប៉ាល់ ឬប្រទេស ឥណ្ឌា ។ តាមរយៈនេះ ប្រជាជនមូលដ្ឋានក៏អាចទទួលបានកម្រៃសមល្មមសំរាប់ផ្គត់ផ្គង់ជីវភាពរបស់ពួកគេដែរ ។

ការនាំកុមារឱ្យទស្សនាសត្វព្រៃ ឬសារៈមន្ទីរធម្មជាតិ គឺជាកាយវិការល្អមួយទៀត ដែលអប់រំកុមារឱ្យចេះអង្កេតលក្ខណៈធម្មជាតិ ឬដំណើរជីវិតរបស់សង្គមសត្វព្រៃ និងបរិស្ថានជុំវិញខ្លួនរបស់ពួកគេ ។ ជាការពិតណាស់ថា កាលណាពួកគេមានគំនិតយល់ដឹងអំពីដំណើរធម្មជាតិយល់បានអំពីការប្រព្រឹត្តទៅរបស់សង្គមសត្វ ឬមនុស្ស កុមារា និងកុមារីទាំងនោះនឹងមានសុជីវធម៌ខ្ពស់សំរាប់ជីវិតប្រចាំថ្ងៃរបស់គេផងដែរ ។ ហើយសង្គមដែលមានមនុស្សប្រកបដោយសុជីវធម៌បែបនេះ ដែលយើងចង់បានទាំងអស់គ្នា ។

ការទស្សនាសោភ័ណភាពសត្វព្រៃ ពិសេសការគយគន់ចរិតលក្ខណៈរបស់បុគ្គលសត្វនិមួយៗ ឬដំណើរសង្គមគ្រួសារនៃប្រភេទសត្វនិមួយៗអាចនាំឱ្យមនុស្សបំភ្លេចការនឿយហត់ ឬទុក្ខព្រួយបានយ៉ាងច្រើន ។ អ្នកទេសចរធម្មជាតិមានអារម្មណ៍កាន់តែរីករាយថែមទៀតនៅពេលដែលគេឃើញសត្វព្រៃធ្វើចលនាហាច់ហើរ ឬប្រលែងគ្នាលេង ។ សត្វខ្លា គោ និងសត្វព្រៃមាឌធំៗដទៃទៀតគឺជាគោលបំណងនៃដំណើរកំសាន្តរបស់អ្នកទេសចរធម្មជាតិ ។ ឧទាហរណ៍ នៅ

ប្រទេសឥណ្ឌា ឬណេប៉ាល់ អ្នកទេសចរចង់ឃើញខ្លាដំបង រីឯនៅអាហ្វ្រិកខាងត្បូងអ្នកទេសចរចង់ឃើញសត្វប្រាំធំៗ (ដែលភាសាអង់គ្លេសហៅថា Big 5) (រមាស គោ ដំរី ក្របីព្រៃ និងសត្វកវែង/giraf) ។

### ១.៣.៤ ផ្នែកវិទ្យាសាស្ត្រ

អេកូឡូស៊ីសត្វព្រៃ និងទំនាក់ទំនងរបស់វាជាមួយនឹងព្រៃឈើជាគំរូមួយឱ្យមនុស្សសិក្សា និងទាញយកចំណេញសំរាប់ការដាំដំណាំ ឬចិញ្ចឹមសត្វស្រុក ។ ដូចបាននិយាយមកហើយថាប្រភេទមនុស្សបានរៀនពីធម្មជាតិ និងកែច្នៃធម្មជាតិយកមកប្រើប្រាស់ក្នុងសង្គមរបស់ខ្លួន ។ ការធ្វើសំបុក ឬទ្រុងឱ្យសត្វស្រុកពង កូន និងការផ្សំចំណីសត្វស្រុកដែលបានទទួលជោគជ័យក៏ដោយសារការអង្កេត ការសាកល្បងពីគំរូអេកូឡូស៊ីរបស់សហគមន៍សត្វព្រៃដែរ ។ អ្នកជំនាញសួនសត្វទាមទារឱ្យមានចំណេះដឹងទូលំទូលាយអំពីអេកូឡូស៊ីដើម ឬលំនៅដ្ឋានដើម (កំណើត) របស់ប្រភេទសត្វព្រៃទើបគេទទួលបានជោគជ័យក្នុងការរៀបចំ ថែទាំ និងអភិវឌ្ឍន៍សួនសត្វ ។ លើសពីនេះ សួនសត្វចំហ[២] រីឯរឹតតែទាមទារឱ្យមានចំណេះដឹងអេកូឡូស៊ីសត្វព្រៃ និងសហគមន៍របស់វានេះកាន់តែច្រើនឡើងថែមទៀត ព្រោះគេត្រូវដឹងថាធ្វើដូចម្តេច ដើម្បីមិនឱ្យសត្វ (ស្លាប) រត់គេចពីតំបន់សួនសត្វចំហនេះ ។

ការយកសត្វព្រៃជាវត្ថុពិសោធន៍សំរាប់សិក្សាអំពីដំណើរចិត្តសាស្ត្ររបស់មនុស្ស ។ សត្វព្រៃមួយចំនួន ដូចជាស្វា ជាដើម ត្រូវបានគេប្រើប្រាស់ដើម្បីពិសោធន៍ឱសថសម័យ (ទំនើប) មុននឹងដាក់ឱ្យប្រើប្រាស់ ឬលក់នៅលើទីផ្សារសំរាប់ព្យាបាលមនុស្ស ។ ដោយសារសត្វស្វាជាប្រភេទសត្វមានសន្ដានជិតទៅប្រភេទមនុស្សជាងគេ ក្រុមគ្រូពេទ្យបាន និងកំពុងប្រើប្រាស់ប្រភេទសត្វ

---

[២] សួនចំហ គឺជាសួនដែលគេលែងសត្វព្រៃក្នុងបរិវេណដីធំ (២-៥ហាត) ។ របងសង់ព័ទ្ធជុំវិញសួនទាំងមូល តែសត្វព្រៃត្រូវបានលែងនៅខាងក្នុងសួន នេះ ។ សត្វព្រៃភាគច្រើនមិនត្រូវបានគេដាក់ក្នុងទ្រុងតូចៗ (៤ម គុណ ៤ម ឬ ៥ម គុណ ៦ម) ទេ ។

ស្ថានានា ដើម្បីយកមកសាកពិសោធន៍ប្រសិទ្ធិភាពនៃឱសថសម័យសំរាប់ព្យាបាលជម្ងឺផ្សេងៗ ។ លោក ដាសម៉ាន់ (Dasmann) បញ្ជាក់ថា ស្នែងរបស់ប្រភេទសត្វប្រើសត្រូវបានគេយកទៅប្រើសំរាប់ជាសន្ទស្សន៍បង្ហាញអំពីជាតិវិទ្យុសកម្មនៅក្នុងបរិស្ថាន ។

ការស្រាវជ្រាវរកវិធីសាស្ត្របំបាត់សត្វល្អិតចង្រៃដែលបំផ្លាញដំណាំកសិកម្ម គឺជាការចំណាយដ៏ធំនៅក្នុងវិស័យនេះ ។ រហូតដល់ពេលនេះគេនៅតែឃើញកសិករប្រើថ្នាំគីមី ដែលនាំឱ្យគេចំណាយថវិកាយ៉ាងច្រើនក្នុងរដូវដាំដុះ ។ ទន្ទឹមនេះ កសិករអាចកាត់បន្ថយចំណាយបានច្រើន បើគេរកឃើញប្រភេទសត្វដែលស៊ីសត្វល្អិតចង្រៃជាអាហារ ។ លទ្ធផលដែលគេទទួលបានពីយកសត្វឱ្យស៊ីសត្វល្អិតចង្រៃជាអាហារនេះមានភាគច្រើននៅបណ្តាប្រទេសជឿនលឿន ពិសេសនៅលើកសិដ្ឋានធំៗ (១០០ហត ឬច្រើនជាងនេះ) ។

<u>សំរាប់ទស្សនា:</u> នៅពេលពួកគេធ្វើដំណើរទស្សនា អ្នកទេសចរធម្មជាតិ ឬទេសចរសត្វព្រៃមានការរីករាយណាស់ បើពួកគេបានឃើញសត្វធំៗ ដូចជា ខ្លាដំបង ដំរី ។ល។ ។ អ្នកទេសចរកាន់តែរីករាយ និងនិយមនាំគ្នាទៅទស្សនាទៀតនោះគឺនៅពេលដែលសំភារៈបំពាក់សំរាប់បំរើឱ្យវិស័យទេសចរណ៍កាន់តែមានផាសុខភាពឡើង ។ គឺថា គេអាចជិះដំរីបណ្តើរ ឬជិះរថយន្តបណ្តើរមើលសត្វកំពុង ស៊ីស្មៅបណ្តើរ ។

ចំពោះសួនសត្វវិញ កូនខ្លាជាច្រើនបានកើតនៅក្នុងសួន ។ កូនកាត់ជំនាន់ក្រោយៗ ដែលមានដើមកំណើតពីមេបាក្នុងសួនសុទ្ធសាធច្រើនតែមានការធន់នឹងជម្ងឺទាប ។ អ្នកវិទ្យាសាស្ត្រសួនសត្វបានរកឃើញថា ការបង្កាត់បងប្អូនឯងជាច្រើនដងរវាងសត្វខ្លាមេ និងបាអាចទទួលគ្រោះថ្នាក់ដល់ពូជសត្វខ្លាទាំងមូល ។ ជាឧទាហរណ៍ សួនសត្វបណ្តាប្រទេសក្នុងសមាគមន៍ប្រជាជាតិអាស៊ានបានជួបក្នុងបញ្ហានេះ ហើយគេនាំគ្នាធ្វើការដោះដូររវាងកូនខ្លាពីក្នុងសួនជាមួយនឹងកូនខ្លាព្រៃ (ដែលចាប់បានពីព្រៃ) ។

មិនខុសគ្នាពីសត្វ និងរុក្ខជាតិព្រៃ ដំណាំស្រូវក៏មានលំនាំប្រហាក់ប្រហែលគ្នាដែរ ។ វិស្វករដំណាំស្រូវបាន និងកំពុងសិក្សាស្រាវជ្រាវទិន្នផលស្រូវពីជំនាន់មួយទៅមួយទៀត ។ ពេលខ្លះគេ

យកដំណាំស្រូវពីតំបន់មួយទៅបង្កាត់ជាមួយនឹងពូជស្រូវនៅតំបន់មួយទៀត ហើយពេលខ្លះទៀតគេយកស្រូវព្រៃមកធ្វើជាកត្តាជំរុញឱ្យទិន្នផលស្រូវស្រុកមានការកើនឡើង ។

ការសិក្សាអំពីសត្វព្រៃអាចឱ្យគេរកឃើញបច្ចេកទេសថ្មីៗដែលយកលំនាំតាមដំណើរការរស់នៅរបស់សត្វព្រៃ ឬដំណើរជីវសាស្ត្ររបស់វា ។ បច្ចុប្បន្ននេះ គេកំពុងធ្វើការបង្កាត់ផ្កាកេសរ (ផ្កាអ័រគីដេ) ព្រៃជាមួយនឹងផ្កាស្រុក ។ គេធ្វើបែបនេះព្រោះថាការបង្កាត់ផ្កា អ័រគីដេស្រុកជាមួយគ្នាវាច្រើនជំនាន់ពេកទៅ (លើសពី ៥ដង) នាំឱ្យពណ៌របស់ផ្កាមិនសូវមានសម្រស់ ។ រីឯពណ៌របស់ផ្កាអ័រគីដេព្រៃមានសម្រស់ល្អជាង ។ ហើយសូម្បីតែផ្កាកូនកាត់ក៏មានសម្រស់ស្រស់ជាងផ្កាអ័រគីដេស្រុកសុទ្ធដែរ ។ លើសពីនេះទៀត ផ្កាអ័រគីដេព្រៃអាចមានក្លិនប្រសើរជាងទៀតផង ។

សំរាប់ជាមធ្យោបាយដឹកអ្នកទេសចរ : អ្នកទេសចរធម្មជាតិមានចំណូលចិត្តជិះដំរីដើរកំសាន្តព្រៃណាស់ ។ គេចង់ទទួលអារម្មណ៍អំពីការជិះដំរីថាតើវាមានលក្ខណៈបែបណា ។ ក្រៅពីយានយន្តទំនើបៗ នាពេលបច្ចុប្បន្ននេះមានក្រុមហ៊ុនដំរីមួយក្រុមកំពុងទទួលបំរើអ្នកទេសចរបរទេស និងក្នុងស្រុកនៅសៀមរាបអង្គរវត្ត ។ អ្នកទេសចរបរទេសចូលចិត្តជួលដំរីជាមធ្យោបាយធ្វើដំណើរណាស់ ។

## ១.៤ ធនធានធម្មជាតិសត្វព្រៃ

### ធនធានសត្វព្រៃ និងការអភិរក្ស

ធនធានធម្មជាតិត្រូវបានគេបែងចែកជាពីរយ៉ាងគឺ "**ធនធានជីវៈ**" (biotic resource) និង "**ធនធានអជីវៈ**" (abiotic resource) ។ ធនធានជីវៈ រួមមាន រុក្ខជាតិ សត្វព្រៃ និងធនធានធម្មជាតិដទៃទៀតដែលអាចកើត (ដុះ) ឡើងវិញបានក្រោយពីមានការធ្វើអាជីវកម្ម ឬប្រើប្រាស់ ។ រីឯធនធានអជីវៈធម្មជាតិ រួមមាន រ៉ែគ្រប់ប្រភេទ ថ្ម (សិលា) និងធរណីដែលមិនអាចកកើតឡើងវិញបានបន្ទាប់ពីត្រូវគេធ្វើអាជីវកម្មម្តងរួចហើយ ។ គេអាចចោទថា "ទឹក" (ពីទឹកលើដី ទៅទឹកភ្លៀង ទៅទឹកលើដី វិញ) អាចចាត់ទុកជាធនធានជីវៈដែរ ព្រោះវាកើត

ហើយបាត់ទៅវិញ រួចកើតវិញទៀត ។ ប៉ុន្តែ យើងនៅតែចាត់ទុកថាទឹកគឺជាធនធានអជីវៈ ព្រោះបរិមាណរបស់វាមិនបាត់បង់ទេ នៅក្នុងដំណើររងការប្រើប្រាស់វានោះ ។ ចំណោទមួយទៀតគឺបើក្នុងរយៈពេលរាប់លានឆ្នាំ ដីអាចកើតឡើងវិញពីសិលា ធ្យូងថ្មអាចកើតឡើងវិញពីសារធាតុឈើដែលកប់ក្នុងដី ឬរ៉ែប្រេងកាតអាចកកើតឡើងវិញពីសារធាតុសរីរាង្គ ។ ប៉ុន្តែ ការកកើតឡើងវិញនៃរ៉ែទាំងនេះទាមទាររយៈពេលរាប់លានឆ្នាំបែបនេះ យើងមិនចាត់ទុកជាធនធានជីវៈទេ ។

អភិរក្សធនធានធម្មជាតិ ឬអភិរក្សសត្វព្រៃគឺការបង្កលក្ខខ័ណ្ឌ (ប្រើប្រាស់ ឬមិនប្រើប្រាស់) ឬធានាលក្ខខ័ណ្ឌអត្ថិភាពរបស់វាដើម្បីឱ្យវាបន្តវត្តមានពូជពង្សជាបន្តទៀត ។ ការរក្សាពូជនៃប្រភេទសត្វព្រៃនិមួយៗឱ្យនៅគង់វង្ស និងមានលទ្ធភាពបន្តបង្កើតប៉ូពុយឡាស្យុង (population) តទៅទៀតគឺជាគោលបំណងសំខាន់បំផុតរបស់ការអភិរក្ស ។ ដោយសារគេមិនបានធ្វើការអភិរក្សទើបសត្វព្រៃមួយចំនួនដូចជា រមាសកុយមួយ (Rhiniceros sondaicus) គោព្រៃ (Bos sauveli) បានផុតពូជពីទឹកដីកម្ពុជា ទើបតែនៅប្រមាណ ៣០-៤០ឆ្នាំ មុននេះ ។ នៅពេលបច្ចុប្បន្ន ខ្លាដំបង (Panthera tigris) កំពុងស្ថិតក្នុងស្ថានភាពងាយផុតពូជដោយសារការធ្វេសប្រហែសនឹងសកម្មភាពអភិរក្ស ។

ស្មសាន្តភាព (Wilderness) គឺជាសភាពវិវត្តរបស់សហគមន៍សត្វព្រៃ និងរុក្ខជាតិដោយធម្មជាតិពីដំណាក់មួយដល់ដំណាក់មួយទៀត ។ ស្មសាន្តភាពជាធនធានធម្មជាតិដែលគេត្រូវតែថែរក្សាដំណើរការរបស់វា ព្រោះវាផ្សារភ្ជាប់នឹងការរស់នៅរបស់មនុស្ស ឬព្រោះវាជាបរិស្ថានរបស់មនុស្ស ។ ស្មសាន្តភាពមិនគ្រាន់តែជាអ្វីៗដែលមាននៅក្នុងព្រៃដូចជាដី ថ្ម ព្រៃឈើ ។ល។ នោះទេ តែគឺគុណភាពនៃបណ្តុំរបស់ស្មសាន្ត ដែលមនុស្សមិនអាចបង្កើតបាន និងមានតម្លៃមិនអាចកាត់ថ្លៃបានចំពោះបរិស្ថានរបស់មនុស្ស ។ ការការពារ ថែរក្សា (អភិរក្ស) ទីស្មសាន្តទាំងមូលឱ្យរក្សាបានសភាពដើមរបស់វា គឺជាការចាំបាច់នៅព្រមពេលជាមួយនឹងការប្រើប្រាស់

ផល-អនុផលតិចតួចពីស្មសាន្តនោះ ។ ធ្វើបែបនេះបានទើបអាចរក្សាស្ថានភាពទីស្មសាន្ត និង ស្មសាន្តភាពបាន ហើយការទទួលផលពីប្រភពនោះ ក៏ចេះតែមានជាបន្តបន្ទាប់ ។

សត្វព្រៃចាត់ទុកជាធនធានជីវៈធម្មជាតិមួយប្រភេទក្នុងចំណោមធនធានធម្មជាតិដទៃទៀតដែលបំរើផលប្រយោជន៍ដល់មនុស្សជាតិ ។ សត្វព្រៃជាធនធានជីវៈ ដែលបន្តផ្តល់ផលពីជំនាន់មួយដល់ជំនាន់មួយទៀត ។ ធនធានជីវៈជំនាន់មួយអាចនឹងរលាយបាត់ទៅវិញតាមអាយុកាលរបស់វា បើទោះជាត្រូវបាន ឬមិនត្រូវបានមនុស្សប្រើប្រាស់វាក៏ដោយ ។ ឧទាហរណ៍ ខ្ទីង (Bos gaurus) ១ក្បាលបានកើតមកហើយ មានវ័យចាស់ រួចនឹងងាប់ (រលាយ) បាត់ទៅវិញ ដោយខ្ទីង១ក្បាល ឬច្រើនក្បាលទៀត (ជាកូនរបស់វា ឬកូនខ្ទីងដទៃមួយទៀត) កើតមកជំនួសវិញ ហើយដំណើរនេះចេះតែបន្តកើត ស្លាប់ ក្នុងលក្ខខ័ណ្ឌបរិស្ថានមួយសមស្របរបស់វា ។

ការប្រើប្រាស់ធនធានជីវៈអាចនាំទៅដល់ផល ០២យ៉ាងគឺ "ការប្រើប្រាស់ដោយចីរភាព និងដោយគ្មានចីរភាព" ។ ការប្រើប្រាស់ដោយចីរភាពគឺការប្រើប្រាស់ធនធានជីវៈដែលបានគិតគូរអំពីការធានាការផ្តល់ផលនៅជំនាន់ក្រោយៗទៀត ។ ឧទាហរណ៍ ប្រើស ១ក្បាល ត្រូវបានគេដកចេញ (ប្រមាញ់) ពីហ្វូង ១ដែលមាន ១០ក្បាល នៅឆ្នាំទី ១ ហើយ ២ក្បាលទៀត ត្រូវបានគេដកចេញនៅឆ្នាំបន្ទាប់ (ទី ២) បើគេឃើញហ្វូងវាបានកើនដល់ ១៥ក្បាល ។ ការដកធនធានជីវសត្វព្រៃបែបនេះទើបអាចរក្សាបានចីរភាពរបស់ប្រភេទសត្វប្រើស ។ រីឯការប្រើប្រាស់ធនធានជីវៈសត្វព្រៃដោយគ្មានចីរភាពគឺការដកយកចំនួនសត្វប្រើសដែលបណ្តាលឱ្យសល់ចំនួនប្រើស តិចឡើងៗនៅក្នុងហ្វូងរបស់វាពីមួយឆ្នាំទៅមួយឆ្នាំទៀត ។

**យើងត្រូវតែបន្តរក្សាការផ្តល់ផលរបស់**
**សត្វព្រៃជាបន្តទៀត !**

# ជំពូក ២ សត្វព្រៃនៅកម្ពុជា

តាមសណ្ឋានដីប្រទេសកម្ពុជា ដែលមានភាពផតទាបនៅតំបន់កណ្តាលជុំវិញបឹងទន្លេសាប និងតាមដងទន្លេមេគង្គបាន និងកំពុងអំណោយផលដល់វិស័យកសិកម្ម និងការអភិវឌ្ឍន៍ដទៃៗទៀត នៅក្នុងតំបន់នេះ ។ តំបន់ព្រៃឈើចំនួនពីរត្រូវបានហែកដាច់ពីគ្នា ដោយសារសកម្មភាពរបស់មនុស្សរហូតមកដល់ពេលបច្ចុប្បន្ននេះ នោះគឺ តំបន់ឥសាន និងតំបន់ជួរភ្នំក្រវាញ ។ តំបន់ឥសានរួមមាន ខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី រីឯតំបន់ជួរភ្នំក្រវាញគឺមានខេត្តកំពង់ស្ពឺ ពោធិ៍សាត់ កោះកុង និងខេត្តប៉ៃលិន ។ ការរីក រាលកាន់តែធំឡើងៗនៃផ្ទៃដីកសិកម្មពីតំបន់អាងទន្លេមេគង្គ បឹងទន្លេសាប និងទន្លេសាបឆ្ពោះទៅតំបន់ខ្ពង់រាប-ជើងភ្នំ ឬតំបន់ភ្នំបែបនេះបាន និងកំពុងនាំឱ្យផ្ទៃដីព្រៃឈើ និងចំនួនសត្វព្រៃ ទាំងចំនួនប្រភេទ ទាំងចំនួនសត្វ ថយចុះជាបណ្តើរៗដែរ ។ ការរីករាលផ្ទៃដីកសិកម្ម និងលំនៅដ្ឋានរបស់មនុស្សនៅតំបន់នេះអាចបណ្តាលមកពីមូលហេតុធំៗចំនួនពីរគឺ ការកើនឡើងចំនួនមនុស្ស និងគោលនយោបាយអភិវឌ្ឍន៍របស់រដ្ឋាភិបាល ។ ដំណាក់កាលចាប់ផ្តើមរីករាលដីកសិកម្មនេះជាសំខាន់ គឺនៅក្នុងរបបខ្មែរក្រហម និងជាបន្តបន្ទាប់មក ។ ក្នុងរបបខ្មែរក្រហមនេះដែរ យើងបានដឹងថាមានការប្រើប្រាស់ និងពឹងផ្អែកលើធនធានធម្មជាតិព្រៃឈើ និងសត្វព្រៃជាចំបងសំរាប់ការទ្រទ្រង់សេដ្ឋកិច្ចសហករណ៍ ភូមិភាគ និងជាតិទាំងមូល ។ ជាឧទាហរណ៍ ពួកគេបានពឹងផ្អែកលើធនធានសត្វព្រៃសំរាប់ជាប្រភពសាច់ដើម្បីផ្គត់ផ្គង់សហករណ៍នៅពេលទន្ទឹមគ្នានឹងការជន្លៀសដោយបង្ខំឱ្យមនុស្សទូទាំងប្រទេសធ្វើស្រែ-ចំការ និងលើកទំនប់ ជីកប្រឡាយតាមតំបន់ទំនាបៗទូទាំងប្រទេស ។

ប៉ុន្តែ ទោះបីមានការថយចុះនៃចំនួនសត្វព្រៃក្នុងរបបដូចបានពោលខាងលើហើយក៏ដោយក៏ចំនួនសត្វព្រៃនៅមានជាបង្គួរដែរ ។ ចំនួនសត្វព្រៃបន្តថយចុះកាន់តែខ្លាំងថែមទៀតក្នុងអំឡុងពេលនៃទសវត្សឆ្នាំ ១៩៨០ ១៩៩០ និងដើមទសវត្សឆ្នាំ ២០០០ ដោយសារ តម្រូវការទីផ្សារជាតិ និងអន្តរជាតិ ព្រមគ្នាជាមួយនឹងភាពធូររលុងនៃការអនុវត្តន៍ច្បាប់ ។

## ២.១ ប្រវត្តិនៃការគ្រប់គ្រងព្រៃឈើ-សត្វព្រៃ

ជីវិតមនុស្ស សត្វ និងរុក្ខជាតិមានការពឹងអាស្រ័យគ្នាទៅវិញទៅមកយ៉ាងចាំបាច់ជាទីបំផុត និងមិនអាចកាត់ផ្ដាច់បានឡើយ ។ តាមរបកគំហើញផូស៊ីលបានបញ្ជាក់ឱ្យយើងដឹងថាមនុស្សជំនាន់ដើមធ្វើការប្រមាញ់សត្វព្រៃ ត្រី និងម្រឹគដទៃទៀត ដោយដុំថ្ម អង្កត់ឈើ ហើយបរិភោគសាច់ និងអាហារឆៅ ។ ដោយសារការវិវត្តិន៍នៃខួរក្បាល និងការរកឃើញភ្លើងដោយចៃដន្យ មនុស្សបានប្រើប្រាស់ភ្លើងសំរាប់ចំអិនអាហារ និងអាចធ្វើដំណើរបានឆ្ងាយៗពីរូង ឬល្អាងថ្មដែលជាលំនៅឋានរបស់ខ្លួន ។ គេប្រើប្រាស់ភ្លើងធ្វើដំណើរពីតំបន់អេក្វាទ័រ (នៅទីនោះត្រូវបានអ្នកមនុស្សសាស្ត្រសន្មតថាជាកន្លែងកកើតពូជសាស្ត្រមនុស្សមុនគេ) ឆ្ពោះទៅទិសខាងជើង ឬខាងត្បូងនៃភូគោល ដើម្បីស្វែងរកអាហារ និងសេចក្ដីត្រូវការផ្សេងៗទៀត ។ គួរបញ្ជាក់ផងដែរថា ក្នុងជំនាន់មនុស្សបុព្វកាល (រាប់ម៉ឺនឆ្នាំមុនគ្រឹសករាជ) គេជួបប្រទះនឹងអាកាសធាតុត្រជាក់ខ្លាំងណាស់ (យុគសម័យទឹកកក) ហើយមនុស្សបានចាប់កំណើតមុនគេបង្អស់នៅតំបន់អេក្វាទ័រ (ទ្វីបអាហ្វ្រិក) ដែលជាតំបន់មានកំដៅគ្រប់គ្រាន់សំរាប់ជីវិតរបស់ពួកគេ ។ តាំងពីពេលនោះរហូតមកដល់ពេលសព្វថ្ងៃនេះគេនៅតែឃើញការដកថយនៃភ្នំទឹកកកពីតំបន់ត្រជាក់បង្គួរ និងជាបណ្ដើរៗពីតំបន់ប៉ូល ដូចជាកោះ អាឡាស្កា ជាដើម (នៅពេលនេះ គេប្រើប្រាស់កោះអាឡាស្កាជាតំបន់ទេសចរណ៍ទឹកកក ដែលទាក់ទាញមនុស្សទៅទស្សនារាប់លាននាក់ក្នុងមួយឆ្នាំៗ) ព្រមពេលគ្នាជាមួយនឹងការប្រើ ប្រាស់ភ្លើង ឬកំដៅកាន់តែច្រើនឡើងៗរបស់មនុស្ស ។

អាកាសធាតុប្រែប្រួល កំដៅឡើងខ្ពស់ជាបណ្ដើរៗ ព្រមគ្នាជាមួយនឹងការប្រើប្រាស់ភ្លើង (ការចំអិនអាហារ ដែលក្នុងនោះមានសាច់សត្វព្រៃផងដែរ ការប្រើប្រាស់គ្រឿងចក្រដោយប្រេងឥន្ធនៈ) កាន់តែច្រើនឡើងៗនាំឱ្យព្រៃឈើក៏ងាយឆាបឆេះដោយសារបាតុភូតធម្មជាតិ ឬដោយសារសកម្មភាពរបស់មនុស្សទោះដោយចេតនា ឬអចេតនាក្ដី ។ ការស្រាវជ្រាវរបស់លោកអានឌ្រូ (Andrew Maxwell ១៩៩៩) នៅតំបន់បឹង យក្សឡោម ខេត្តរតនគីរីបានកត់

សំគាល់ឱ្យឃើញថា ភ្លើងព្រៃបានបន្តឆាបឆេះតំបន់ព្រៃល្បោះនៅជុំវិញខេត្តនេះ ឬនៅក្នុងភូមិភាគអាស៊ីអគ្នេយ៍នេះតាំងពី ១០០០ឆ្នាំ រហូតមកដល់ពេលសព្វថ្ងៃនេះ ។ ប៉ុន្តែ ទោះបីមានការប្រែប្រួលបែបខាងលើនេះក៏ដោយ ក៏ការប្រើប្រាស់ធនធានធម្មជាតិតាំងពីពេលនោះរហូតដល់អំឡុងពេលប៉ុន្មានពី ៥០ ទៅ ១០០ឆ្នាំ កន្លងមក នេះមិនសូវមានសភាពធ្ងន់ធ្ងរគួរឱ្យព្រួយបារម្ភដូចការប្រើប្រាស់ធនធានធម្មជាតិដូចរយៈពេលពី ៥ ទៅ ២០ឆ្នាំ កន្លងមកថ្មីៗនេះទេ ។ តាមការទស្សន៍ទាយជាច្រើនបានបង្ហាញថាធនធានព្រៃឈើសកលលោកអាចនឹងថយចុះជាបន្តទៀត បើគេនាំគ្នាប្រើប្រាស់វាក្នុងសភាពដូចសព្វថ្ងៃនេះ ។ ទំនោរនេះ គឺដោយសារកត្តាសំខាន់ៗដូចជាកំណើនមនុស្ស ការប្រជែងគ្នាប្រមូលផលធនធានធម្មជាតិ និងសកលភាវូបណីយកម្ម ។

តាមការសិក្សារបស់អង្គការ FAO លោក Chris និង Durst (២០០៣) បានបង្ហាញថា ដីព្រៃឈើបានថយចុះ ០,៨% នៃផ្ទៃដីព្រៃឈើក្នុងតំបន់អាស៊ីភាគអគ្នេយ៍ក្នុងឆ្នាំ ១៩៩៩-២០០០ ។ ទន្ទឹមនេះគេក៏ឃើញមានការកើនដីព្រៃឈើនៅក្នុងតំបន់អាស៊ីខាងជើង (សាធារណរដ្ឋប្រជាមានិតចិន) ដែរគឺប្រមាណ ១% នៅក្នុងឆ្នាំខាងលើនេះ ដោយសារការដាំព្រៃឡើងវិញ និងដោយសារការបញ្ឈប់ច្បាប់អាជីវកម្មឈើទូទៅ ។ រីឯនៅកម្ពុជាផ្ទៃដីព្រៃបានប្រែប្រួលពី ៧៣% នៃផ្ទៃដីប្រទេសនៅមុនឆ្នាំ ១៩៧០ មកនៅប្រមាណ ៥៩% នៅឆ្នាំ ២០០៤ ។

អ្វីដែលយើងចង់ចៀសវាងនោះ គឺការបំពានលើកំហុសដែលទាំងអស់គ្នាបានដឹង កំពុងតែដឹង ហើយនឹងនៅតែដឹង ប៉ុន្តែមិនព្រមចង់ធ្វើដឹងហើយចូលរួមជួយគ្នាដោះស្រាយ ។

## ...នៅពេលតួនាទីព្រៃឈើកាន់តែមានច្រើនឡើង ផ្ទៃដីព្រៃឈើកាន់តែថយចុះ...

ផលសត្វព្រៃត្រូវបានប្រជាពលរដ្ឋខ្មែរប្រើប្រាស់សំរាប់ជាទំនិញ ឬថ្នូរដើម្បីប្តូរយកកំណាត់សំពត់ ឬអំបោះ ខោអាវជាមួយនឹងអ្នកជំនួញជនជាតិចិន តាំងពីមុនសម័យអង្គរមកម្ល៉េះ (លីធាបតេង ១៩៧៣) ។ ដូចនៅបណ្តាប្រទេសដទៃទៀតដែរ ជីវភាពប្រជាពលរដ្ឋកម្ពុជាមាន

ទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងផល-អនុផលសត្វព្រៃ ។ សិលាចារឹកជាច្រើនបានចារឹកទុកនូវសកម្មភាពប្រើប្រាស់ និងសារៈសំខាន់នៃធនធានសត្វព្រៃចំពោះជីវភាព : ថនិកសត្វ រួមមានពពួកតិណាសី មំសាសី និងត្រី ជាដើម ហើយនិងបន្លែផ្លែឈើជាច្រើនប្រភេទទៀត ដូចមានរូបភាពសត្វព្រៃដែលត្រូវបានចារឹកនៅតាមប្រាសាទនានានៃតំបន់ និងក្នុងសម័យអង្គរវត្ត ។ បឹងទន្លេសាប និងតំបន់ទំនាបលិចទឹកជុំវិញបឹងនេះជាប្រភពផ្តល់ធនធានសត្វព្រៃដ៏សំបើម និងមិនបេះរឹងស្ងួតនៅកម្ពុជា ។ តាមសិលាចារឹកទាំងនេះ ឆ្លុះបញ្ចាំងថាកំលាំងមនុស្សដ៏មហិមា ដែលបានចំណាយសាងសង់ប្រាសាទអង្គរ និងប្រាសាទដទៃទៀត គឺអាចទទួលបានពីប្រូតេអ៊ីន និងបន្លែផ្លែឈើព្រៃដទៃទៀតពីតំបន់ខាងលើនេះ ។ ដោយហេតុយល់ឃើញពីសារៈសំខាន់ និងអំណោយទានធម្មជាតិ ដែលមិនអាចបំភ្លេចបាននេះហើយទើបបុព្វបុរសខ្មែរអង្គរបានចារឹកធនធានទាំងនេះនៅលើប្រាង្គប្រាសាទនានានោះ ។ អាចនិយាយម្យ៉ាងទៀតថា ដោយសារធនធានសត្វព្រៃនៅតំបន់អង្គរមានអំណោយផលច្រើនមិនអាចកាត់ថ្លៃបាន និងដោយសាររបកគំហើញធារាសាស្ត្រ-កសិកម្ម ( បារាយណ៍) មុនគេនៅក្នុងតំបន់អាស៊ីអគ្នេយ៍នេះ មហាបុរសខ្មែរ ឬនគរខ្មែរជារួមបង្កើតបានជានគរមួយដែលមានឈ្មោះល្បីល្បាញ ជាងគេក្នុងតំបន់ ។

រូប ២.១ : សត្វព្រៃ និងត្រីក្នុងជីវភាពប្រជារាស្ត្រសម័យមហានគរ





### ២.១.១ សម័យអាណាព្យាបាលបារាំង

ក្នុងដំណើររុករកផលប្រយោជន៍ពីធនធានធម្មជាតិ នៅកន្លែងផ្សេងៗ នៅលើផែនដីយើងនេះ ក្នុងអំឡុងឆ្នាំ ១៧០០-១៨០០ និង ១៩០០ បារាំងបានមកសំចតនៅជ្រោយឥណ្ឌូចិន ហើយបានចូលមកដាក់អាណាព្យាបាលរបស់ខ្លួននៅកម្ពុជាជាផ្លូវការនៅឆ្នាំ ១៨៦៣ រហូតដល់ឆ្នាំ ១៩៥៤ (Kiernan 1985) ។ យើងឃើញទន្លេមេគង្គគឺបានជាផ្លូវដឹកជញ្ជូនសំខាន់ជាងគេនៅក្នុងតំបន់អាងទន្លេមេគង្គភ្ជាប់ទៅនាវាចរសមុទ្រ ។ ទន្លេមួយទៀតដែលបារាំងបានប្រើប្រាស់ ដឹកផល-អនុផលព្រៃឈើចេញពីតំបន់ឥណ្ឌូចិនគឺទន្លេហៃហ្វុង ដែលចុះសមុទ្រត្រង់ពាមហៃហ្វុង (Hai Phong) តំបន់ទីក្រុងហាណូយ វៀតណាមខាងជើង ។ ជាការពិតបេសកជន ឬអ្នកជំនួញបារាំងចេញចូលភ្នំពេញតាមទន្លេមេគង្គ ប៉ុន្តែអ្នកស្រាវជ្រាវ និងអ្នកជំនួញផល-អនុផលព្រៃឈើសត្វព្រៃបានធ្វើដំណើររុក រកផលនៃធនធានធម្មជាតិតាមដីគោកពីទីក្រុងព្រៃនគរឆ្លងកាត់តាមខេត្តជាច្រើននៃប្រទេសវៀតណាម (ខេត្តដាក់ឡាក់ ដាក់មីល សុងប៊ែ ។ល។) ឆ្ពោះមកបណ្តាខេត្តឥសានកម្ពុជា ដូចជា មណ្ឌលគិរី រតនគិរី ក្រចេះ ។ល។

ក្រុមខ្លះទៀតនៃអ្នកជំនួញបារាំង-កម្ពុជាបានរុករកតំបន់ដីក្រហម ដើម្បីដាំដើមកៅស៊ូ ។ នៅឆ្នាំ ១៩១០ បារាំងបាននាំដើមកៅស៊ូមកដាំនៅតំបន់ព្រៃនប់ (ក្រុងព្រះសីហនុបច្ចុប្បន្ន) រួចបានពង្រីកផ្ទៃដីដាំជាបន្តបន្ទាប់នៅកម្ពុជា (ឃុន កក្កដា ២០០៥) ។ ការរក ឃើញតំបន់ដីក្រហម និងការពង្រីកផ្ទៃដីដាំកៅស៊ូនៅចំការលើ ជប់ និងមេមត់ ក្នុងខេត្តកំពង់ចាមនៅទសវត្សឆ្នាំ ១៩៤០ និងដើម ទសវត្សឆ្នាំ ១៩៥០ គឺបានធ្វើឡើងនៅលើដីព្រៃឈើធម្មជាតិ និងសត្វព្រៃ (ហ៊ាន ឈាង ១៩៩៦) ។ គឺនៅក្នុងអំឡុងអភិវឌ្ឍន៍ ដំណាំ កៅស៊ូនេះហើយ ដែលកើតឡើងនូវការបរបាញ់សត្វព្រៃ (ខ្លា ដំរី ខ្លាឃ្មុំ និងសត្វផ្តល់សាច់ដ៏ពេញនិយមដទៃទៀតដូចជាឈ្លូស ប្រើស) ក្នុងទ្រង់ទ្រាយធំគួរឱ្យចាប់អារម្មណ៍ ។ នៅពេលនោះប្រជាពលរដ្ឋអបអរសាទរនឹងការសំលាប់ខ្លាណាស់ព្រោះទី១ ខ្លាស៊ីគោ ឬសត្វពាហនៈរបស់ពួកគេ ហើយសំខាន់ជាងគេគឺខ្លាខាំសំលាប់អ្នកភូមិ (កូនក្មេង ឬស្ត្រី) ដែលនៅដាច់ស្រយាល (ហ៊ាន ឈាង ១៩៩៦) ។

ការបន្តដាំកៅស៊ូ និងការពង្រីកផ្ទៃដីដាំកៅស៊ូនៅតែបន្តរហូតមកដល់ពេលបច្ចុប្បន្ន បើទោះបីអាណាព្យាបាលបារាំងបានចាកចេញពីកម្ពុជាកាលពីឆ្នាំ ១៩៥៤ ហើយក៏ដោយ ។ ទីជម្រកសត្វព្រៃនៅក្រៅតំបន់ការពារ និងនៅក្នុងតំបន់ការពារនៅតែរងការទន្ទ្រាន និងថយទំហំជាបណ្ដើរៗដោយសារតែសម្ពាធភាពអភិវឌ្ឍន៍ និងការទាមទារដីកសិកម្ម ។

តាមឯកសារនានាដែលបានចងក្រងអំពីការងារគ្រប់គ្រងវិស័យព្រៃឈើបានបង្ហាញឱ្យឃើញថា ព្រៃឈើនៅកម្ពុជាបានត្រូវចាប់ផ្ដើមធ្វើចង្វាក់ការងារចាប់តាំងពីឆ្នាំ ១៩០១ មកម្ល៉េះ ។ ជាការពិតដំណើរការគ្រប់គ្រងវិស័យនេះចាប់ផ្ដើមឡើងដំបូងៗបានធ្វើឡើង តែលើការដកយកពន្ធអាករពីអ្នកលក់ផលព្រៃឈើនៅទីផ្សារប៉ុណ្ណោះ ។ គេពុំបានគិតគូរដកពន្ធអាករពីការរកផលអនុផលព្រៃឈើនៅ ឯក្នុងព្រៃឈើសោះឡើយ ។ ការងារបច្ចេកទេសថែរក្សាព្រៃឈើនៅក្នុងតំបន់ព្រៃឈើក៏ពុំមានដែរក្នុងអំឡុងពេលដំបូងៗនៃការគ្រប់គ្រងព្រៃឈើ ។ តាមឯកសារដដែលទាំងនោះទៀតបានបញ្ជាក់ថា ប្រជារាស្ត្រមានសិទ្ធិប្រើប្រាស់ព្រៃឈើ និងដីព្រៃឈើដោយពុំមានការឃាត់ឃាំងណាសោះឡើយ ។ ពួកគេអាចកាប់ឆ្ការដីព្រៃឈើសាងសង់លំនៅដ្ឋាន ឬដើម្បីមុខងារផ្សេងទៀតតាមចិត្តប៉ងប្រាថ្នា ។ ការងារដកពន្ធអាករនេះចេះតែមានការវិវត្តន៍ប្រែប្រួលជារឿយៗតរៀងមក (ឡៅប៊ុនហាក់ ១៩៧២) ។ ការបរបាញ់សត្វព្រៃក៏កាន់តែបើកចំហទៅទៀត ។ ប្រជាពលរដ្ឋប្រមូលផលសត្វព្រៃដើម្បីយកទៅធ្វើជាថ្នូរជាមួយនឹងសំពត់ ខោអាវជាមួយឈ្មួញសំពៅចិន ឬតណ្ហាដោយសេរី ។

ក្នុងអំឡុងពេលដើមដំបូងនៃអាណាព្យាបាល (អាណានិគមនិយម) បារាំងពីឆ្នាំ ១៨៦៣ ដល់ ១៨៩៨ គេពុំទាន់ឃើញមានការគ្រប់គ្រងព្រៃឈើតឹងតែងនៅឡើយទេ ។ ប៉ុន្តែ បន្ទាប់ពីមានការគ្រប់គ្រងព្រៃឈើឆ្នាំ ១៩០១ មកការរៀបចំជាបណ្ដុំការងារគ្រប់គ្រងវិស័យនេះបានកាន់តែមានភាពតឹងតែងឡើងៗ ។ ព្រមពេលនោះដែរ គេបានរៀបចំចងក្រងបណ្ដាបទដ្ឋាន

នានាដើម្បីធ្វើការគ្រប់គ្រងវិស័យព្រៃឈើ[៣] ដែលហៅថាការគ្រប់គ្រងធនធានព្រៃឈើឱ្យមាននិរន្តរភាព ។ គួរបញ្ជាក់ផងដែរថា លិខិតបទដ្ឋានទាំងនោះភាគ ច្រើនផ្តោតទៅលើការគ្រប់គ្រងព្រៃឈើជារួមនៅឥណ្ឌូចិន (កម្ពុជា ឡាវ កូសាំងស៊ីន អាណាម និងតុងកឹង) ។ ប្រទេសកូសាំងស៊ីន អាណាម និងតុងកឹងបានក្លាយជាប្រទេសវៀតណាមចាប់តាំងពីឆ្នាំ ១៩៧៥ មក (សូមមើលផែនទី ២.១.១) ។ ក្នុងសម័យអាណាព្យាបាលបារាំង ឈើហ៊ុប និងផលិតផលព្រៃឈើភាគច្រើនត្រូវគេនាំចេញទៅបរទេសច្រើនជាងការប្រើប្រាស់ក្នុងស្រុក (Institut, 1970) នៃប្រទេសក្នុងឥណ្ឌូចិននេះ ។ ការធ្វើអាជីវកម្មឈើ និងអនុផលព្រៃឈើផ្សេងទៀត (ស្ទើរតែទាំងអស់) នៅក្នុងប្រទេសកម្ពុជាក្នុងសម័យអាណាព្យាបាលបារាំង គឺត្រូវបានគេធ្វើឡើងដោយមានការអនុញ្ញាតពីតំណាងរដ្ឋាភិបាលបារាំងប្រចាំឥណ្ឌូចិន (Résident Supérieur de l' Indochine) ។ ដូចគ្នានេះដែរ ធនធានសត្វព្រៃដែលរួមមានភ្លុកដំរី ស្បែក ឬឆ្អឹងខ្លា (ដូចជាខ្លាដំបង ជាដើម) ត្រូវបានឈ្មួញ ទាំងបារាំង ទាំងកម្ពុជាធ្វើការនាំចេញទៅបរទេសដូចជាប្រទេសចិន ឬជប៉ុន ជាដើម ។

មធ្យោបាយអាជីវកម្មឈើហ៊ុបនាសម័យអាណាព្យាបាលបារាំងគឺភាគច្រើនប្រកបដោយពលកម្មមនុស្ស និងសត្វពាហនៈ រាប់តាំងពីរទេះក្របី ដំរី និងការបណ្តែតក្បូន ។ ការកាត់ឈើ ក៏ដោយសារកំលាំងពលកម្មមនុស្សដែរ គឺដោយពូថៅ ដឹង និងរណារដៃ ។ គេបានធ្វើការបណ្តែតក្បូនឈើហ៊ុបចុះតាមព្រែកឆ្លូង ស្ទឹងត្រង់ ចុះតាមទន្លេមេគង្គឆ្ពោះទៅភ្នំពេញ រួចទៅប្រទេសកូសាំងស៊ីន (វៀតណាម ភាគខាងត្បូងសព្វថ្ងៃនេះ) និងនាំចេញទៅប្រទេសទីបី ។ គួរបញ្ជាក់ផងដែរថា តាមឯកសារនានាដែលបន្សល់ទុកដោយបណ្ណាល័យ Centre des Archives d' outre mer នាខេត្ត Aix En Provence ប្រទេសបារាំង គេបានធ្វើការនាំចេញមាឌឈើរាប់លាន

---

[៣] "វិស័យព្រៃឈើ " មានន័យថា "ព្រៃឈើ និងសត្វព្រៃ" ។
ការគ្រប់គ្រងវិស័យព្រៃឈើគឺការគ្រប់គ្រងព្រៃឈើ និងសត្វព្រៃ ។ ជាធម្មតា ការគ្រប់គ្រងវិស័យព្រៃឈើនៅសម័យនោះគឺផ្តោតជាសំខាន់ដល់ការប្រមូលផលឈើ អនុផលព្រៃឈើ និងសត្វព្រៃ។

ម៉ែតត្រីគុណក្នុងមួយឆ្នាំៗពីប្រទេសកម្ពុជា ទោះជាការធ្វើអាជីវកម្មឈើខាងលើនេះដោយពលកម្មមនុស្ស និងសត្វពាហនៈក៏ដោយ ។ តំណភាពនៃការគ្រប់គ្រងព្រៃឈើរបៀបអាណាព្យាបាលបារាំងបានបន្តនៅក្រោយសករាជបារាំងរហូតដល់ឆ្នាំ ១៩៧០ ។ នៅក្នុងអំឡុងទសវត្សឆ្នាំ ១៩៧០ ការគ្រប់គ្រងព្រៃឈើមិនមានរចនាសម្ព័ន្ធច្បាស់លាស់ទេព្រោះប្រទេសបានធ្លាក់ក្នុងសង្គ្រាមក្នុងស្រុក និងសង្គ្រាមក្នុងតំបន់ ។ អំឡុងខែ មិនា ឆ្នាំ ១៩៧០ ដល់ មេសា ១៩៧៥ របបសាធារណរដ្ឋខ្មែរបានគ្រប់គ្រងទីផ្សារឈើសំខាន់ៗ តែកងទ័ពរំដោះរបស់ខ្មែរក្រហមគ្រប់គ្រងតំបន់ព្រៃឈើស្ទើរទាំងអស់រួមគ្នានឹងការកាប់ឈើលក់ដោយគ្មានក្បួនខ្នាត ។ លុះអំឡុងឆ្នាំ ១៩៧៥ ដល់ ១៩៧៩ មេដឹកនាំខ្មែរក្រហមបានគ្រប់គ្រងវិស័យព្រៃឈើទាំងមូល (ទាំងទីផ្សារឈើ ទាំងតំបន់ព្រៃឈើ) ប៉ុន្តែគ្មានឯកសារអំពីរចនាសម្ព័ន្ធគ្រប់គ្រងព្រៃឈើទេ ។

ផែនទី ២.១.១ ផែនទីប្រទេសនានាក្នុងឥណ្ឌូចិន និងព័ត៌មានព្រៃឈើ

# CARTE FORESTIÈRE DE L'INDO-CHINE

dressée par M. HENRI GUIBIER

Inspecteur des Eaux et Forêts, Chef du Service forestier de l'Indo-Chine.



### ២.១.២ ឆ្នាំ ១៩៥០ ដល់ ១៩៧០ : ការដាក់តាំងតំបន់បំរុងសត្វព្រៃ

ក្នុងដំណើររុករកផលប្រយោជន៍ពីធនធានធម្មជាតិសត្វព្រៃ និងព្រៃឈើរបស់ក្រុមធ្វើអាណានិគមបារាំង បារាំងបានប្រឹងប្រែង ប្រមូលផលទាំងនោះឱ្យច្រើនដែលអាចធ្វើបាន ។ ភ្លុកដំរី ស្បែកខ្លាដំបង កុយរមាស ឬវត្ថុមានតម្លៃពីសត្វព្រៃដទៃទៀតត្រូវបានបារាំង និងឈ្មួញក្នុងសម័យនោះប្រមូលយកដោយអស់ទំហឹង ។ កាយវិកាដ៏គួឱ្យកោតសរសើរនោះគឺ ការថែរក្សាពូជសត្វព្រៃ ។ ដោយមានសំពាធពីក្រុមអ្នកវិទ្យាសាស្ត្រសត្វព្រៃបារាំង និងរដ្ឋាភិបាលក្រោមបង្គាប់បានបង្ខំចិត្តចាត់ទុកតំបន់ព្រៃឈើមួយចំនួនជា "ដែនបំរុងសត្វព្រៃ" ឬ "ឧទ្យានជាតិ" ។ តាមឯកសារលោក ហ្វីលីប ឡឺប៊ីយ៉ុង (១៩៩២) បានបង្ហាញថាមានព្រៃបំរុងសត្វព្រៃចំនួន ១៧៣ កន្លែង ដែលជាគោលបំណងបំរុងទុកសំរាប់ផលព្រៃឈើ ឬធនធានសត្វព្រៃ ។ ប៉ុន្តែ តំបន់បំរុងសត្វព្រៃដែលមានឈ្មោះបោះសម្លេងជាងគេគឺ លំផាត់ គូលែនព្រហ្មទេពដែលមានគោលបំណងសំខាន់សំរាប់អភិរក្ស "គោព្រៃ" ។

### ២.១.៣ ពីសម័យ ១៩៧០ ដល់ បច្ចុប្បន្ន

ក្នុងរយៈពេលចលនាតស៊ូក្នុងអំឡុងឆ្នាំ ១៩៧០-១៩៧៥ មេដឹកនាំខ្មែរក្រហមបានបង្កើតក្រុមប្រមាញ់សត្វព្រៃដើម្បីផ្គត់ផ្គង់សាច់ដល់ក្រុមកងឈ្លប និងក្រុមសាមគ្គីជនបទ ។ មានអតីតព្រានប្រមាញ់ក្នុងជំនាន់នោះចំនួនបីនាក់នៅតំបន់ផ្សេងៗគ្នាគឺ លោក **ហម សុផល** - នៅខេត្តកំពង់ស្ពឺនាតំបន់ជួរភ្នំក្រវាញ លោក **សាត់ ភោគ** - នៅខេត្តស្ទឹងត្រែង និងលោក **យ៉ី ង៉ុន** - នៅខេត្តរតនគិរី នាតំបន់ភូមិភាគឥសាន ដែលបានប្រឡូកក្នុងសកម្មភាពខាងលើ ។ លោកទាំងបីនាក់សុទ្ធតែបានចូលរួមក្នុងការធ្វើប្រមាញ់សត្វព្រៃយកសាច់ផ្គត់ផ្គង់ក្រុមសាមគ្គីក្នុងសម័យតស៊ូខ្មែរក្រហម ។ គោលបំណងរបស់ក្រុមប្រមាញ់ផ្គត់ផ្គង់សាច់សត្វព្រៃក្នុងរបបខ្មែរក្រហមឆ្នាំ ១៩៧៥-១៩៧៩ គឺផ្តោតទៅលើសាច់សត្វព្រៃជាគោលដៅដូចជា ដំរី ទន្សោង ខ្ទីង ប្រើស រមាំង ជ្រូកព្រៃ